# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូបញ្ញាលិក្ខិត កៅ - ស៊ុម អ្នកត្រួតត្រា
សិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* ទំព័រ


អ្នកញ៉ាទេពពិទូរ ព្រំសេម . . . ព្រះរាជប្រវត្តិ សម្ដេចព្រះវត្តិយកល្បាណ៍រាជ-សុតាភគវតី . . . . . . . . . . . . . ៣៩៣

លោកគ្រូចៅអធិការ ឯក-ញឹម . ធម្មិកោវាទ ពាក្យកាព្យ . . . . . . . . . ៣៩៦

លោក ហាន់-យេង . . . . . . រឿងកំពូលកំសត់ (តមក) . . . . . . . . ៤១១

ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម . . ប្រជុំសុភាសិតខ្មែរ តាមលំដាប់អក្សរ (តមក និងចប់) . . . . . . . . . . . . . ៤២៣

លោក ញ៉ុក - នូ . . . . . . ច្បាប់ក្រមបរិយាយ (តមក) . . . . . . . ៤៣០

*ផ្នែកសាសនា*

ដំណឹងអំពីក្រសួងធម្មការ . . . អំពីតាំងចៅអធិការនិងមន្ត្រីសង្ឃ . . . . . . ៤៣៧

ព្រះគ្រូសុវណ្ណញាណ សូរ-កោយ. បរិយាយសិប្បកថា (តមកនិងចប់) . . . . ៤៤២


ឆ្នាំ ១៦ — លេខ ៨ ខែមិនា ឆ្នាំ ១៩៤៤ — ដំរៃប្រចាំ ១ ឆ្នាំ ១៥ រៀល —

# KĂMPŬCHĔASŌRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhique.
Rédacteur en chef de la partie littéraire: Luong Nibandhamantri NHOK-THÊM, Pandit à l'Institut Bouddhique.
Rédacteur en chef de la partie religieuse: Preah kru Paññalikhito KAO-SIM, Surveillant général de l'École Supérieure de Pāli.

## TABLE DES MATIÈRES

**Partie littéraire:**

| | | Pages |
|---|---|---|
| Oknha Tép Pītou Krasem | Biographie de S. A. R. la princesse Sutharot . . . . . . . . . . | 393 |
| Vénérable Chau At'ĭkar Ek-Nhim. . . . . . . | Dhammikovāda, poème. . . . . . | 396 |
| Monsieur Han-Yéng. . . . | Kămpul kămsăt, roman (suite) . . | 411 |
| Luong nĭponmontrei Nhok-Thêm. . . . . . | Recueil de proverbes cambodgiens classés par ordre alphabétique (suite et fin) . . . . . . . . | 423 |
| Monsieur Nbeuk-Nou. . . | Chbáp krămborĭyay (suite). . . . | 430 |

**Partie religieuse:**

| | | |
|---|---|---|
| Communiqué du département des Cultes . . . | Nominations de Chau at'ĭkar et Montrei săng . . . . . . . . . | 487 |
| Prĕah kru Suvaddhaññāna So-Hay. . . . . . . | Pariyāyasippakathā (suite et fin). | 442 |

# ព្រះរាជប្រវត្តិ

# សម្ដេចព្រះខត្តិយកល្យាណីរាជសុតាភគវតី

## ព្រះរាជអយ្យិកា

ទ្រង់ប្រសូតនៅថ្ងៃអង្គារ ខែកត្តិកឆ្នាំចឆស័ក ព. ស. ២៤១៧ (គ. ស. ១៨៧៤)

ទ្រង់សុគតនៅវេលារសៀលម៉ោង ៤ ដប់បីមីនុតក្នុងថ្ងៃពុធ ១៣ កើតខែស្រាពណ៍ឆ្នាំមមែសប្តស័ក ព. ស. ២៤៩៩ (២ អ៊ូត ១៩៥៥) ដោយព្រះរោគខ្យល់ ដំណឹងនេះជាទីសោកសោកនៃព្រះរាជវង្សានុវង្ស និងនាហ្មឺនសព្វមុខមន្ត្រីនូវប្រជារាស្ត្រទាំងពួងជាយ៉ាងក្រៃពេក ។

សម្ដេចព្រះរាជអយ្យិកាព្រះនាមដើម " ផង់ង៉ាំម " ជាព្រះបិយៈធីតានៃព្រះករុណា ព្រះបាទសម្ដេចព្រះនរោត្តមបរមទេវាវតារ ព្រះចៅក្រុងកម្ពុជាធិបតី និងលោកឃុនចៅចមមាតាសុជាតបុប្ផា (នាម នួន) នៅថ្ងៃ – ខែ – ឆ្នាំដូចបានពោលមកហើយ ។ លុះចំរើនវ័យឡើង ហើយបានទ្រង់សមរស និងសម្ដេចព្រះរាជអយ្យកោវរចក្រណរិទ្ធ នរោត្តម-សុធារស កាលពីក្នុង ព. ស. ២៤៣៧ គ. ស. ១៨៩៤ មានព្រះរាជបុត្រព្រះរាជធីតារួមទាំងអស់ ៧ អង្គ ។ តែគង់ព្រះជន្មនៅសព្វថ្ងៃនេះតែ ២ ព្រះអង្គគឺ :

១ – ព្រះរាជបុត្រ : សម្ដេចព្រះវររាជបិតា វិសុទ្ធខត្តិយវង្ស ន. សុរាម្រឹត ដ៏ជាព្រះរាជបិតានៃព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង

វដ្ដកាលបច្ចុប្បន្ន, (ក្នុងពេលមុនដែលព្រះករុណាបានឡើងសោយរាជ-សម្បត្តិ ទ្រង់ធ្វើការងារដំណែងជាសេនាបតី ទីចក្រញ៉ា (ក្រឡាហោម) ។

២– ព្រះរាជធីតា: សម្ដេចព្រះបុត្រាស្មើសោភ័ណ ។

## អំពីព្រះបរិយាសម្បត្តិ នូវព្រះគុណសម្បត្តិ

ពោលដោយសង្ខេប: សម្ដេចព្រះរាជអយ្យិកានេះមានព្រះបរិយាសុភាពស្រគត់ស្រគំមានព្រះហឫទ័យត្រជាក់ត្រជុំ-ទូលាយ តែងទ្រង់ព្រះមេត្តាប្រោសកប់អាននិងទំនុកបម្រុងព្រះរាជវង្សានុវង្ស នូវនាហ្មឺនសព្វមុខមន្ត្រី ព្រមទាំងប្រជារាស្ត្រ អ្នកទីទ័លក្រឲ្យបានសេចក្ដីសុខចូលទៅ ទ្រង់មានព្រះអធ្យាស្រ័យរីករាយ គួរជាទីក្រេបផឹកដោយចិត្តរបស់អ្នកដែលបានឃើញ ឬសមាគមផង ទ្រង់ជាមហាសប្បុរសមានសីលវត្តល្អ តែងទ្រង់ព្រះសណ្ដាប់ព្រះធម្មទេសនា និងបរិច្ចាគទានក្នុងបវរពុទ្ធសាសនាជានិច្ច ព្រមទាំងទក្ខិណាកម្មដែលជាទីគន់ជាទីគោរពទៅមកច្បាប់ ហែមិនដែលដាច់នៃព្រះសង្ឃសក្យបុត្រទាំងឡាយ ។

ក្រៅអំពីព្រះគុណសម្បត្តិផ្ទាល់ព្រះអង្គទាំងនេះ ទ្រង់បានផ្ដើមបង្កើតសាលាបង្រៀនកុមារី ហៅថា "សាលាសម្ដេចក្សត្រីសុធារស" (P. Sutharoth) នៅក្នុងភ្នំពេញ ជាទីបណ្ដុះបណ្ដាលចំណេះវិជ្ជាដល់កុមារីទាំងឡាយក្នុងព្រះនគរ ទ្រង់បានយកព្រះហឫទ័យទុកដាក់ចំណាយព្រះរាជទ្រព្យផ្ទាល់ព្រះអង្គជាប្រចាំទំនុកបម្រុងសាលានេះឲ្យបានសេចក្ដី

ចំរើនដរាបមកដល់សព្វថ្ងៃនេះ នឹងទ្រង់បានទទួលដំណែងជាសមាជិកាមន្ទីរស្រមាលបុត្រស្រមាប់ជាតិខ្មែរ ជាមួយនឹងលោកស្រីឌូសេក មួយអន្លើទៀតជាដើម សឹងកប់ថាជាប្រយោជន៍ដល់ស្រីខ្មែរជាអនេកប្រការ ។

ដោយទ្រង់បំពេញ អត្ថហិតប្រយោជន៍ផ្ទាល់ព្រះអង្គនិងបរហិតប្រយោជន៍ដល់អ្នកដទៃ និងដល់រាជការដូច្នេះ ទើបមានជនានុជនក្នុងព្រះនគរនិយមគោរពរាប់អានទូទៅ ទ្រង់បានទទួលព្រះកិត្តិយសខ្ពស់ គឺជាសម្តេចព្រះខត្តិយ៉ាបេកល្យាណ៍រាជសុភាគគវតី តាំងពីក្នុងរជ្ជកាលព្រះករុណាបរមខត្តិយកោដ្ឋ មកក្នុងរជ្ជកាលបច្ចុប្បន្ននេះ ទ្រង់បានឡើងព្រះកិត្តិយសជាសម្តេចព្រះរាជអយ្យិកាខត្តិយកល្យាណ៍រាជសុភាគគវតី ទាំងរាជការអាណាព្យាបាលក៏បានថ្វាយគ្រឿងឥស្សរិយយស ១ សំដែងសេចក្តីអំណរក្នុងគុណបំណាច់ដែលទ្រង់យកព្រះហឫទ័យទុកដាក់ធ្វើករណីយកិច្ចផ្សេងៗ សឹងជាប្រយោជន៍ក្នុងព្រះនគរដរាបមក ។

ជម្ពីកោភ ឌ

# ព្រះអាចារ្យ ឯក-ញឹម ធម្មិស្សរោ

ចៅអធិការវត្តធម្មិស្សរការាម ស្រុកសូទ្រនិគម ខេត្តសៀមរាប

រៀបរៀង

ក្បាច់ធម៌ក្នុងសៀវភៅនេះ យើងខ្ញុំ ធម្មិស្សរោ (ឯក-ញឹម) ចៅអធិការនៃវត្តធម្មិស្សរការាមរៀបរៀងឡើងជាពាក្យឃ្លោង សម្រាប់ក្មេងរៀននៃវត្តធម្មិស្សរការាម នៅថ្ងៃពុធ ៩ កើតខែស្រាពណ៍ ឆ្នាំមមែបញ្ចស័ក ព.ស. ២៤៨៦ ។

ក្បាច់ធម៌ទាំងអស់ដែលយើងខ្ញុំដកស្រង់មករៀបរៀងនេះ នៅមានសេចក្ដីពិស្ដារក្នុងសិង្គាលោវាទសូត្រ ។

ឯរបៀបធម៌ក្នុងសូត្រនោះ មិនមែនបែបនេះទេ ប៉ុន្តែយើងខ្ញុំអ្នកតែងយល់ថាគួររៀបចំឡើងជារបៀបថ្មី ដើម្បីស្រួលតាមទំនងបុព្វការី និងកតញ្ញូកតវេទីបុគ្គល ដែលជាបុគ្គលរកបានដោយក្រ ២ យ៉ាងក្នុងលោក ។

លុះយើងខ្ញុំរៀបចំរួចហើយ បានយកក្បាច់នេះបង្រៀនដល់ពួកកុលបុត្រអ្នកបួសថ្មីៗ ក្នុងវត្តរបស់យើងខ្ញុំ ប៉ុន្តែកាលបង្រៀននោះ យើងខ្ញុំបានយកបាលីមកតាំងទុកជាគោល ចងជាឃ្លាកាព្យឡើងតាមស្ពាន ហើយឱ្យមានព្រមទាំងសេចក្ដីប្រែនៃពាក្យឃ្លោងនេះផង ។

គមកមានពុទ្ធបរិស័ទជាច្រើនគ្នាជ្រះថ្លាចង់បានធម៌នេះ ទើបនាំគ្នាចាត់ការបោះពុម្ពផ្សាយចែកជាធម្មទានក្នុងឱកាសបុណ្យបញ្ចុះសីមាវត្តនោះ នៅថ្ងៃអាទិត្យ ១១ កើតខែមិគសិរឆ្នាំរកាស័ក ព.ស. ២៤៩៧ ប៉ុន្តែដោយហេតុក្រដាសរកបានដោយកម្រណាស់ ក្នុងសម័យសព្វថ្ងៃនេះ ទើបយើងខ្ញុំយកមកជូនពុទ្ធសាសនបណ្ឌិត្យ ដើម្បីចាត់ចែងបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយានេះ ។

យើងខ្ញុំសូមសេចក្ដីសុខចំរើន ចូរមានដល់ព្រះពុទ្ធសាសនិកជន លោកអ្នកសិក្សាទាំងឡាយផង ដល់នគរក្រុងកម្ពុជា និងមហានគរជាពិសេស ដែលបានជួយឧបត្ថម្ភ ដល់ពុទ្ធសាសនា និងប្រទេសជាតិផង តទៅអស់កាលជាអង្វែង ។

## ទិសានមស្សការធម៌ ៦ យ៉ាង

### បទពាក្យប្រាំពីរ

ទី ១– ខាងកើតទិសបុព្វ ទុកជាមាតាបិតា
ដែលបង្កើតបុត្រក្នុងលោក គួរកូនស្នេហាអស់ពីចិត្ត ។
ត្រូវប្រតិបត្តិលោកដោយធម៌ប្រាំ ដែលអ្នកប្រាជ្ញផ្តាំមានកំរិត
កំដរថ្លៃគុណលោកអាណិត ដោយមេត្តាចិត្តជួយកូនថ្លៃ ។
ទី ២– ខាងត្បូងទិសទក្ខិណា ទុកជាអាចារ្យយើងសព្វថ្ងៃ
ដែលបង្រៀនធម៌ល្អថ្លាថ្លៃ ឲ្យបាននិស្ស័យទៅនិព្វាន ។
ត្រូវប្រតិបត្តិលោកដោយធម៌ប្រាំ ដែលអ្នកប្រាជ្ញផ្តាំទុកទូន្មាន
គឺពាក្យជាច្បាប់ឧភទាន ទាំងនោះត្រូវមានចិត្តជ្រះថ្លា ។

ទី៣– ខាងលិចទិសបច្ឆិមា　　នោះលោកទុកជាបុត្តភរិយា
ដែលនៅក្រោយខ្នងយើងរាល់គ្នា　　នោះគឺជាក្រោមបង្គាប់ខ្លួន ។
ត្រូវធ្វើសង្គ្រោះដោយធម៌ប្រាំ　　ដែលអ្នកប្រាជ្ញផ្ដាំផ្ដាច់មាំមួន
ជាត្រូវមានចិត្តអាណិតស្ងួន　　កុំមានគុំគួនឬធ្ងន់ធ្ងាញ់ ។
ទី៤– ខាងជើងទិសឧត្តរ　　លោកទុកថាជាមិត្រសំឡាញ់
ដែលមានចិត្តស្មើតគ្នាលង្វាញ់　　រាប់អានស្រឡាញ់ឥតអាក់ឡើយ ។
ត្រូវប្រតិបត្តិគ្នាដោយធម៌ប្រាំ　　ដែលអ្នកប្រាជ្ញផ្ដាំផ្ដាច់មកហើយ
បើមិត្រមានទុក្ខជួយឲ្យស្បើយ　　កុំខានសោះឡើយទើបត្រូវធម៌ ។
ទី៥– ខាងក្រោមទិសហេដ្ឋា　　លោកទុកជាទាសកម្មករ
ដែលជួយធ្វើការអាក្រក់ល្អ　　ដោយចិត្តស្មោះសរនឹងចៅហ្វាយ ។
ត្រូវនាយសង្គ្រោះដោយធម៌ប្រាំ　　ដែលអ្នកប្រាជ្ញផ្ដាំឲ្យខ្វល់ខ្វាយ
បើមានឈឺចាប់មិនសប្បាយ　　ត្រូវឲ្យចៅហ្វាយថែរក្សា ។
ទី៦– ខាងលើទិសឧទ្ធៈ　　ទុកជាសមណៈនិងព្រាហ្មណា
ដែលយើងទាយកទាយិកា　　មានចិត្តជ្រះថ្លាហើយធ្វើទាន ។
ត្រូវប្រតិបត្តិលោកដោយធម៌ប្រាំ　　ដែលអ្នកប្រាជ្ញផ្ដាំទុកទូន្មាន
លោកអ្នកប្រាប់ផ្លូវសួគ៌និព្វាន　　ថាទៅដោយយានគឺសីលអើយ ។

# ច្បាប់មាតាបិតាសង្គ្រោះកូន ៥ យ៉ាង

*បទពាក្យប្រាំពីរ*

ទី១– ត្រូវឃាត់កូនទាំងឡាយ　　កុំឲ្យខ្វល់ខ្វាយក្នុងការបាប
សម្លាប់លួចប្លន់នាំផ្ទុនផាប　　អំពើជាបាបឃាត់ឲ្យបាន ។
ទី២– ត្រូវនាំកូនធ្វើបុណ្យ　　អំពើជាគុណតាប់កល្យាណ
ទានសីលជាដើមដែលនាំប្រាណ　　បានសុខក្សេមក្សាន្តឥតទុក្ខភ័យ ។
ទី៣– នាំកូនរៀនសិល្បសាស្ត្រ　　ឲ្យចេះនឹងប្រាស់ទាំងប្រុសស្រី
រៀនទាំងផ្លូវធម៌ផ្លូវលោកិយ　　កុំឲ្យសល់អ្វីសព្វវិជ្ជា ។

ទី៤– ត្រូវរៀបកូនប្រុសស្រី ឲ្យមានស្វាមីឬភរិយា
សមគួរដល់ជាតិធនវ័យវា កុំឲ្យខុសគ្នាតាំអភ័ព ។
ទី៥– ត្រូវបែងចែកធនធាន តាមដោយខ្លួនមានឲ្យគួរជាប់
ឲ្យកូនបានធ្វើជាដើមទ្រព្យ ជាកេរ្តិ៍ត្រកូលគាប់បំផុតអើយ ។

# ច្បាប់កូនប្រតិបត្តិមាតាបិតា ៥ យ៉ាង

ទី១– ត្រូវចិញ្ចឹមរក្សា មាតាបិតាដោយគបគុណ
ដែលលោកធ្វើមកលើខ្លួនមុន ចូរកុំភ្លេចគុណធ្ងន់នោះឡើយ ។
ទី២– បើលោកមានការងារ ត្រូវជួយធ្វើការលោកឲ្យហើយ
បើការស្ទួនគ្នាជួយឲ្យស្មើយ ឬជួយឲ្យហើយក៏គួរគាប់ ។
ទី៣– រក្សាវង្សត្រកូល ចងបាច់ប្រមូលញាតិឲ្យជាប់
ទោះមានទោះក្រត្រូវតែរាប់ រក្សាជាតិទ្រព្យកុំឲ្យបាត់ ។
ទី៤– បើបានទ្រព្យធនធាន ដែលលោកឲ្យទានកុំឲ្យខ្ចាត់
ធ្វើខ្លួនឲ្យគួរដល់សម្បត្តិ ចតិកលោកបាត់ចែកមកឲ្យ ។
ទី៥– ត្រូវធ្វើបុណ្យជូនផល ផ្សាយជូនទៅដល់លោកញយ៉ម
ទោះរស់ទោះស្លាប់ត្រូវធ្វើឲ្យ កុំភ្លេចគុណ ឡើបរណាកូនអើយ ។

# ច្បាប់គ្រូអាចារ្យសង្គ្រោះសិស្ស៥ យ៉ាង

*បទព្រហ្មគីតិ*

១– ខ្លួនគ្មានប្រដៅ សិស្សដែលទៅរៀនធម៌
ទេះច្បាប់រៀបរយល្អ ការណាត្រូវឲ្យភ្ជង់វៃ ។
២– ឲ្យសិស្សសិក្សា ដោយភាពជាប់ប្រពៃ
បង្ហាត់ឲ្យឈ្លាសវៃ ឲ្យយល់ន័យសព្វវិជ្ជា ។
៣– ឲ្យសិស្សសិក្សា សិល្បសាស្ត្រផងនានា
ឲ្យទេះគ្រប់វិជ្ជា កុំភ្ជង់ភព្វលាក់ទុក ។

៤— ធើអាមាត្យ គ្រូ　　មានមកជិតត្រូវលើកទុក
ថ្លែងគុណ សួរសួមសុខ　　ឲ្យគេទុកចិត្តជឿបាន ។
៥— ប្រាប់អត្ថវិជ្ជា　　ធ្វើការពារសព្វភូមិស្ថាន
គេសួរសិស្សឆ្លើយបាន　　មិនរំខានចិត្តសិស្សឡើយ ។

## ច្បាប់សិស្សប្រតិបត្តិគ្រូអាចារ្យ ៥ យ៉ាង

១— ទទួលដំណើរ　　ឬជូនដើរត្រឡប់ទៅ
ទីឋានដែលលោកនៅ　　នេះជាផ្លូវត្រូវគួរសម ។
២— ចូលទៅបំរើ　　តាមកាលធ្វើឲ្យឧត្តម
បោរីថាបំរើធំ　　លោកនិយាយយកពេលបី ។
៣— ជឿស្តាប់ពាក្យគ្រូ　　កុំមួទូកើតអប្រិយ
ឧភទដាស់ដី　　ត្រូវតប្បកាន់ហ្មតចត់ ។
៤— បំរើប្រក្រតី　　ធ្វើការអ៊ុតតកំណត់
ពេលណាមិនប្រាកដ　　នេះជាបទបំរើគួច ។
៥— លោកប្រាប់សិល្បសាស្ត្រ　　ស្តាប់ឲ្យច្បាស់ធ្វើឲ្យដូច
រក្សាកុំឲ្យខូច　　ទាំងធំតូចត្រូវគោរព ។

## ច្បាប់ស្វាមីសង្គ្រោះភរិយា ៥ យ៉ាង

១— រាប់អានភរិយា　　ដោយវាចាដំទន់ភ្លន់
បើគោលទៅប្រពន្ធ　　ពាក្យនោះទន់គួរជាប់ចិត្ត ។
២— មិនមានមើលងាយ　　មិនជេរភិយដោយអាណិត
បេះដូងរក្សាចិត្ត　　ដោយអាណិតនាងភរិយា ។
៣— មិនបានក្បត់ចិត្ត　　ទៅប្រព្រឹត្តស្រីឯនា
ពាឌដោយល្បែងពាណ　　ឲ្យភរិយាក្តៅក្រហាយ ។
៤— បានប្រគល់យស　　យ៉ាងខ្ពង់ខ្ពស់ឲ្យសប្បាយ
យសស្រីផងទាំងឡាយ　　គង់ទុលទាយជើងក្រានផ្ទះ ។

៥– ផ្គត់ផ្គង់ប្រដាប់ មាឧសម្រាប់យាំឧសម្រោង
គ្រឿងអប់គ្រឿងតែងតាំង ពាចក់លាំងធន់ទ្ធចអើយ ។

# ច្បាប់ភរិយាប្រតិបត្តិស្វាមី ៥ យ៉ាង

១– បាត់ចែងការងារ តិតរួញរាដោយផ្ចិតផ្ចង់
ជាយព្រឹកជាយថ្ងៃត្រង់ មិនបង្អង់ខុសវេលា ។

២– ពួកញាតិស្វាមី ទាំងប្រុសស្រីក្មេងវុទ្ធា
សង្គ្រោះស្មើមុខញា ដូចញាតិការខ្លួនស្មោះស្មើ ។

៣– ចេះថែទាំទុក ទ្រព្យដោយមុខតាមដំណើរ
ទ្រព្យអន់ទ្រព្យប្រសើរ ប្រសិនបើស្វាមីឲ្យ ។

៤– មិនបានប្រព្រឹត្ត កន្លងចិត្តស្វាមីឡើយ
ដោយប្រុសដទៃហើយ ដែលនាំឲ្យកើតអន់អាក់ ។

៥– ឈ្លាសព្រមក្នុងការ ហើយឧស្សាហ៍ធ្វើឥតស្រាក់
ជាស្រីវៃគ្រប់ថ្នាក់ មិនមានទាក់ទើសទាល់ឡើយ ។

# ច្បាប់កុលបុត្រសង្គ្រោះមិត្រ ៥ យ៉ាង

១– ឲ្យទ្រព្យគួរឲ្យ មិត្រញយរ ដោយចិត្តជា
ឥតមានគិតរួញរា ស្រឡាញ់ក្នុងដោយចិត្ត ស្មោះ ។

២– បើពោលភាសា ពោលពាក្យណាដែលពីរោះ
រាប់រកគ្នាឥតឈ្លោះ ហើយសង្គ្រោះរក្សាចិត្ត ។

៣– បានធ្វើប្រយោជន៍ តិចយ៉ាងហោចឲ្យដល់មិត្រ
បើមានការជួយគិត ឲ្យតែមិត្របានប្រសើរ ។

៤– បានធ្វើខ្លួនប្រាណ ជាអ្នកមានចិត្តស្មោះស្មើ
មិនមានកិត្តសើរើ តាចដំណើរមិត្រកល្យាណ ។

៥– មិនក្លែងកុហក ពាក្យអាក្រក់កាចសាមាន្យ
ឲ្យមិត្រកើតរវាន ទោះមិនបានពោលសោះឡើយ ។

## ច្បាប់មិត្រប្រតិបត្តិកុលបុត្រ ៥ យ៉ាង

១– កុលបុត្រប្រមាទ　　មិនសំអាតអង្គអាត្មា
ភ្លាត់កាយភ្លាត់វាចា　　ជួយរក្សាក្តីវិបត្តិ ។
២– បានជួយការពារ　　ជួយរក្សាជួយប្រយ័ត្ន
បើធ្វេសក្នុងសម្បត្តិ　　ជួយប្រយ័ត្នយ៉ាងមុះមុត ។
៣– បានធ្វើទីពឹង　　ជាពុំនឹងដល់កុលបុត្រ
គ្រាមានភ័យតក់ស្លុត　　មិនរន្ធត់រត់ចោលគ្នា ។
៤– មិនបានលះបង់　　យកតែអង្គឯកអាត្មា
វិបត្តិជួយរក្សា　　ក្នុងគ្រាណាដែលតក់ស្លុត ។
៥– រាប់អានកូនចៅ　　នូវអស់ចៅពង្សកុលបុត្រ
ដោយចិត្តស្នេហាជុត　　ត្រកូលបុត្រឥតសល់ឡើយ ។

## ច្បាប់ចៅហ្វាយនាយសង្គ្រោះទាសកម្មករ ៥ យ៉ាង

១– ដាក់មុខការឲ្យធ្វើ　　តាមអំពើនឹងកំលាំង
លៃលកតាមខ្សោយខ្លាំង　　ហើយសឹមតាំងឲ្យទទួល ។
២– ឲ្យបាយអាហារ　　នឹងថ្លៃការដល់ពួកឈ្នួល
មិនបានកែកាត់មួល　　ឲ្យតាមដូលប្តេជ្ញាគ្នា ។
៣– បើមានឈឺចាប់　　ស្ទុះប្រញាប់ទៅមើម្នា
ជួយមើលថែរោគា　　រក្សាគ្នាមិនលះបង់ ។
៤– បានចែកអាហារ　　ឆ្ងាញ់ពិសាល្អផ្ទុំផ្គង់
បំពេញតាមចំណង់　　គ្រប់រូបអង្គឥតរួញរា ។
៥– ឲ្យឱកាសឈប់　　សម្រាកគ្រប់កាលវេលា
គួរតាមសម័យភា　　ដែលមានការត្រូវឈប់អើយ ។

# ច្បាប់ទាសកម្មករប្រតិបត្តិចៅហ្វាយនាយ ៥ យ៉ាង

១– ក្រោកឡើងទំរើ | ការសំពើផងនានា
មិនបាច់ចាំគៀនថា | ទៅធ្វើការកំមុននាយ ។
២– ពេលឈប់ធ្វើការ | រលស់វេលាក្រោយចៅហ្វាយ
របស់ផងទាំងឡាយ | បេះទុលទាយយកទុកដាក់ ។
៣– យកតែទ្រព្យណា | នាយអាញ្ញាឲ្យស្មោះស្ម័គ្រ
មិនបានយកលួចលាក់ | នាំឲ្យទាក់កើតទោសទុក្ខ ។
៤– បើធ្វើការណា | ចិត្តឧស្សាហ៍ចង់បានសុខ
ផ្ចិតផ្ចង់ប្រឹងពេញមុខ | យកចិត្តទុកដាក់ក្នុងការ ។
៥– បនតាំគុណនាយ | ទៅទីឆ្ងាយពោលភាសា
សរសើរនាយអញ្ញា | ប្រាប់គេថាល្អណាស់អើយ ។

# ច្បាប់សមណព្រាហ្មណ៍សង្គ្រោះគ្រហស្ថ ៦ យ៉ាង

១ – ការណាជាបាប | ត្រូវប្រាមប្រាប់ហាមគ្រប់មុខ
ព្រោះជាកម្មនាំទុក្ខ | តទៅមុខមានវេរា ។
២ – ការជាកុសល | ជួយនាំផ្តល់ផ្តើមសទ្ធា
សាងទានសីលភាវនា | ដើម្បីជាទីពឹងប្រាណ ។
៣ – បានជួយសង្គ្រោះ | ចិត្តចំពោះធម៌កល្យាណ
មិនធ្វើឲ្យវិនាស | ជួយប្រោសប្រាណដោយស្មោះសរ ។
៤ – បើមិនដែលស្តាប់ | នូវស្នូរស័ព្ទធម៌បវរ
ដឹកនាំឲ្យស្តាប់ធម៌ | ណាដែលល្អប្រសើរគាប់ ។
៥ – ជួយប្រាប់ពន្យល់ | ធម៌ដែលឆ្ងល់ឲ្យយល់ជាប់
ធម៌ណាដែលធ្លាប់ស្តាប់ | ក៏ជួយប្រាប់ឲ្យយល់ឆ្ងាយ ។
៦ – ជួយប្រាប់ផ្លូវធម៌ | ណាដែលល្អកើតសប្បាយ
ឲ្យបានផងទាំងឡាយ | ស្តាប់បរិយាយនៃខ្លួនអើយ ! ។

# ច្បាប់គ្រហស្ថប្រតិបត្តិសមណព្រាហ្មណ៍ ៥ យ៉ាង

១ – មានកាយកម្ម ប្រកបព្រមដោយមេត្តា
បានយកកាយអាត្មា ជួយធ្វើការជាប្រក្រតី ។
២ – មានវចីកម្ម ប្រកបព្រមដោយមេត្រី
បើពោលពាក្យសំដី គួរគប្បីកើតស្នេហា ។
៣ – មានមនោកម្ម ប្រកបព្រមដោយមេត្តា
តាំងនៅក្នុងចិត្ត តែងជ្រះថ្លាក្រាបសំពះ ។
៤ – មានចិត្តសទ្ធា មិនបិទទ្វារបង្អួចផ្ទះ
ធនធានមានហើយលះ ដោយចិត្តជ្រះថ្លាធ្វើទាន ។
៥ – ឧបត្ថម្ភទុក ត្រៀងគ្រប់មុខការស្រេកឃ្លាន
អាមិសដែលខ្លួនមាន លះធ្វើទានឥតអាក់ឡើយ ។

## មិត្តាមិត្តកថា

*សំដែងអំពីបាបមិត្រ គឺមិត្រអាក្រក់ និងកល្យាណមិត្រ គឺមិត្រល្អ ឯបាបមិត្រ មិត្រអាក្រក់នោះ គោលដើមមាន៤ ពួកដូចនេះ:*

*បទពាក្យប្រាំពីរ*

១– មិត្រគិតតែពីចង់បាន របស់ធនធានអំពីមិត្រ
ប្រយោជន៍ខ្លួនឯងនេះតែគិត ប្រយោជន៍ខាងមិត្រឲ្យខាតបង់ ។
២– មិត្រល្អត្រឹមតែវាចា បើពោលពាក្យណាឥតពិតត្រង់
មាត់ឡេទ្យេមិត្រចិត្តឥតចង់ គេចកៃអែអង់ឥតបានឡើយ ។
៣– មិត្របានខាងតែអែបអប ចុះនិយាយប្រឌាក់បណ្ដោយ
ប្រចុបឲ្យមិត្រមានឫស់ឆ្ងោយ ញាក់យសសក្តិដោយសំដីខ្លួន ។

៤— មិត្រនាំឲ្យកើតអន្តរាយ ទ្រព្យធនទាំងឡាយបង់ខ្លួន ។
វិនាសត្រឹមទ្រព្យឬដល់ខ្លួន ដោយក្តីចូលចិត្តគប់មិត្រពាល ។
មិត្រ ៤ ពួកនេះមិនមែនមិត្រ ត្រូវកុំនៅជិតជាដរាប
តែចូលទៅជិតនឹងជាប់បាប ខ្លួននឹងជួបជាប់អន្តរាធាន ។

## ចាប់មិត្រ ៤ ពួកនេះ ក្នុងមិត្រមួយៗ បែកជាបួនៗ តទៅទៀត

### (ក) មិត្រគិតតែពីចង់បាន មាន ៤ ពួកគឺ

១— មិត្រគិតតែពីចង់បាន ប្រយោជន៍ផ្ទាល់ប្រាណគេឥតគិត
២— ឲ្យតិចយកច្រើនអំពីមិត្រ ដោយមានគំនិតគិតរុកគួន ។
៣— បើមានភ័យទើបចេញមុខ ជួយការមិត្រទុកឲ្យជួយខ្លួន
៤— តកជាមិត្រគិតរុកគួន រកប្រយោជន៍ខ្លួនឲ្យបានច្រើន ។
មិត្រ ៤ ពួកនេះមិត្រចង់បាន ប្រយោជន៍ផ្ទាល់ប្រាណឥតបំរើន
ចូរចាំភាសិតច្រើនក្រវើន រំឭកដាស់តឿនកុំភ្លេចឡើយ ។

### (ខ) មិត្រល្អត្រឹមតែវាចា មាន ៤ ពួកគឺ

១— ជួបមុខមិត្រពោលវាចា ថាខ្លួនប្រាថ្នាឲ្យរបស់
២— ពោលតែមាត់ឥតសប្បុរស ថាឆ្នាំនេះអស់ចាំឆ្នាំក្រោយ ។
៣— បើមិត្រធ្វើអំពើណា ក៏ពោលវាចាចាក់បណ្តោយ
៤— ល្អតួរមុខអាក្រក់ក្រោយ មិត្រនេះនាំឲ្យថ្ងួសអស់ខ្លួន ។
មិត្រទាំង ៤ នេះល្អតែមាត់ ចិត្តឥតទៀងទាត់អត់ក្តីស្ងួន
កុំទៅសេពគប់គៅចូចចួន នាំឲ្យថ្ងួសខ្លួនខ្វះអសារ ។

### (គ) មិត្របានខាងឯអបអរ មាន ៤ ពួកគឺ

១— បើមិត្រធ្វើអំពើបាប ក៏ព្រមហើយប្រាប់ថាត្រូវហើយ
២— បើធ្វើបុណ្យជាតោះតើយ ក៏ថាល្អហើយត្រូវធ្វើទៅ ។

៣ — សរសើរគុណមិត្រនៅមុខ    ធ្វើហាក់រួមទុក្ខសុខពេកក្រៃ
៤ — និយាយដើមកេរ្តិ៍អាស្រូវ    ក្នុងពេលមិត្រទៅបាត់ពីមុខ ។
មិត្រទាំង ៤ នេះមិនមែនមិត្រ    កុំឈមឈរជិតនាំមានទុក្ខ
មានទោសដល់ខ្លួនផុតបាត់សុខ    ព្រៀបផ្ចិតគ្រាំផុតត្រូវវៀរចេញ ។

## (ឃ) មិត្រនាំឲ្យអន្តរាយមាន ៤ ពួកគឺ :

១ — មិត្រនាំឲ្យផឹកសុរា    ដែលជាហេតុការណ៍កើតឧបទ្រព
២ — មិត្រនាំឲ្យដើរលេងយប់    តាមច្រកល្ហកគ្រប់ទីកន្លែង ។
៣ — មិត្រនាំដើរមើលមហោស្រព    នាំឲ្យខ្លួនជាប់ចិត្តក្នុងល្បែង
៤ — មិត្រនាំខ្លួនដើរស្ទះស្វែង    ទៅរកលេងល្បែងភ្នាល់ស៊ីសង ។
មិត្រ ៤ ពួកនេះមិនមែនមិត្រ    សេពគប់ខូចចិត្តខាតទ្រព្យផង
កុំរួមសុខទុក្ខខុសបំណង    បំណាច់ខ្លួនប៉ងយកសុខអើយ ។

# កល្យាណមិត្រ  មិត្រល្អគោលដើមមាន ៤ ពួក

## បទពាក្យប្រាំពីរ

១ — មិត្រមានឧបការៈ    គឺមិត្រជាអ្នកជួយឧបត្ថម្ភ
បើខ្លួនភ្លាត់ភ្លាំងក្នុងបាបកម្ម    រំឭកឲ្យចាំដាក់ទៀងបាន ។
២ — មិត្ររួមរួមក្ដីសុខទុក្ខ    គឺមិត្រចេញមុខមកផ្ទាល់ប្រាណ
ជួយរក្សាខ្លួនសព្វភូមិឋាន    ហៅមិត្រកល្យាណរកបានក្រ ។
៣ — មិត្រណែនាំប្រាប់ប្រយោជន៍    ច្រើនតិចដោយហេតុឲ្យតែល្អ
ប្រយោជន៍ផ្លូវលោកឬផ្លូវធម៌    មិត្រនេះរកក្រកំដរខ្លួន ។
៤ — មិត្រមានក្ដីអនុគ្រោះ    ចិត្តស្មោះចំពោះពេញចំនួន
បានជួយស្រោចស្រង់សង្គ្រោះខ្លួន    មិត្រមានក្ដីស្ងួនយ៉ាងបំណាច់ ។
មិត្រ ៤ ពួកនេះចំណានល្អ    ត្រឹមត្រូវតាមធម៌មិត្រពេញច្បាប់
បើមានទំណាក់គួរប្រញាប់    យកជាមិត្រជាប់កុំខានឡើយ ។

## កល្យាណមិត្រ ៤ ពួក

### ក) ក្នុងមិត្រមួយៗ ចែកជាបួនៗ តទៅទៀត

១– បើឃើញមិត្រភ្លាត់ភ្លាំងកាយ    ចូលមកខ្វល់ខ្វាយថែរក្សា
២– បើមិត្រធ្វេសក្នុងទ្រព្យណា    នោះជួយរក្សាទ្រព្យមិត្រឲ្យ ។
៣– បើមិត្រមានភ័យតក់ស្លុត    ក៏មិនបានរត់បោលគ្នាឡើយ
៤– មិត្រត្រូវការរកទ្រព្យហើយ    គ្មានគេចកែឡើយយកឲ្យមិត្រ ។
មិត្រទាំង ៤ នេះមិត្រប្រសើរ    មានហើយគួរដើរចូលទៅជិត
រាប់អានស្រឡាញ់គ្នាយ៉ាងស្និទ្ធ    យកធ្វើជាមិត្រកុំខានឡើយ ។

### ខ) មិត្ររួមសុខទុក្ខមាន ៤ ពួកគឺ:

១– ប្រាប់ការណ៍លាក់បាំងជិត    ដល់ជនជាមិត្រឲ្យដឹងផង
២– បិទការណ៍ដែលមិត្របាន    ប្រាប់ដល់ខ្លួនប្រាណប្រុងការពារ ។
៣– បើការក្រមានដល់មិត្រ    មិនមានគំនិតលះបង់គ្នា
៤– ហ៊ានចេញមុខជួយការពារ    ប្តូរសាប់ឈាមគ្នាប្រយោជន៍មិត្រ ។
មិត្រទាំង ៤ នេះមិត្រម៉ាំមួន    គួរតែងប្តូរខ្លួនប្តូរជីវិត
យកធ្វើជាមិត្រយ៉ាងជិតស្និទ្ធ    ថែរក្សាចិត្តគ្នាទៅហោង ។

### គ) មិត្រណែនាំប្រាប់ប្រយោជន៍មាន ៤ ពួកគឺ:

១– ហាមមិត្រខ្លួនមិនឲ្យធ្វើ    នូវកម្មអំពើជាវេរា
២– នាំឲ្យធ្វើបុណ្យទានា    ដែលជាអំពើបុណ្យកុសល ។
៣– បាននាំស្តាប់ធម៌ទេសនា    ដែលចិត្តអាត្មាមិនដែលស្គាល់
៤– ប្រាប់ផ្លូវសួគ៌ផ្លូវមគ្គផល    ឲ្យបានដឹងដល់ពួកមិត្រនោះ ។
មិត្រទាំង ៤ នេះមិត្រថ្លាថ្លៃ    មិត្រប្រសើរក្រៃជួយសង្គ្រោះ
ណែនាំប្រយោជន៍យ៉ាងខ្ពង់ខ្ពស់    គួរសេពមិត្រនោះកុំខានឡើយ ។

### ឃ) មិត្តមានសេចក្តីអនុគ្រោះមាន ៤ ពួកគឺៈ

១– ឮថាមិត្របង់របស់ ចិត្តគ្មានសោមនស្សត្រេកអរឡើយ
២– ឮថាមិត្រចំរើនហើយ ចិត្តគ្មានកន្តើយជួយត្រេកអរ ។
៣– បានហាមមនុស្សថ្លែងទោសមិត្រ មិនឲ្យប្រព្រឹត្តនិយាយត
៤– សរសើរគេថាចិត្តល្អ ដែលឮគេសរសើរគុណមិត្រ ។
មិត្រទាំង ៤ នេះមានសង្គ្រោះ គួរស្នេហ៍ចំពោះអស់ពីចិត្ត
ត្រូវចងស្នេហាឲ្យបានស្និទ្ធ យកធ្វើជាមិត្រតទៅហោង ។

ចប់លក្ខណមិត្រតែប៉ុណ្ណេះ ។

## អបាយមុខ ធម៌ជាប្រធាននៃសេចក្តីវិនាស ៦ យ៉ាង

*បទពាក្យប្រាំពីរ*

១– ផឹកសុរាឬមេរ័យ រឿយៗ សព្វថ្ងៃដែលជាបាទ
ជាហេតុទីតាំងក្តីប្រមាទ នាំឲ្យមិនស្អាតកើតឧបទ្រព ។
២– ដើរលេងយប់គ្រប់កន្លែង ស្ទះស្ទែងខ្វះវែងដើរពេលយប់
តាមដោយច្រកល្ហកវេលាយប់ នាំខ្លួនឧបទ្រពកើតសៅហ្មង ។
៣– ដើរមើលល្បែងមហោស្រព នាំឲ្យខាតទ្រព្យខូចចិត្តផង
ចូរកុំមើលល្បែងតែងសៅហ្មង កើតទោសទុក្ខផងធំអាត្មា ។
៤– បានលេងល្បែងភ្នាល់ស៊ីសង នាំចិត្តមួហ្មងកើតវេរា
ដោយទោសព្រោះលេងល្បែងនានា ជាហេតុពាលាក្នុងទៅមុខ ។
៥– សេពគប់តែនឹងមិត្របាប ដែលនាំជិនជាប់អង្គឲ្យទុក្ខ
ឲ្យទោសច្រើនក្រៃតទៅមុខ ពុំដែលបានសុខខ្លួនសោះឡើយ ។
៦– ប្រកបខ្លួនក្នុងក្តីខ្ជិល ជាហេតុរេចរឹលគ្រប់មុខ.ហើយ
បានទាន [illegible] មានសេរីយ មិនគួរត្រេកទៅយជាអែបាយ ។

# អបាយមុខ គោលដើម ៦ នេះ

ក្នុងអបាយមុខមួយៗ បែកជាប្រាំមួយៗ តទៅទៀត

### ក) ផឹកសុរាមេរ័យមានទោស ៦ យ៉ាង

១ – វិនាសអស់ទ្រព្យធនធាន    អ្នកផឹកស្រាបានឃើញភ្លែកឯង
២ – កើតប្រកែកឈ្លោះទាស់ទែង    ចំរើនច្រើនស្តែងជាអនេក ។
៣ – បណ្តាលជារោគតាត    មានកើតឡើងជាងនឹតភ្លែក
៤ – កើតនិន្ទាជាអនេក    ពេត្មះតាមភ្លែកគេឃើញនោះ ។
៥ – កេរ្តិ៍ឈ្មោះដែលខ្លួនធ្លាប់លាក់    ក៏បង្ហាញជាក់ភ្លែកគេស្មេះ
៦ – កំលាំងប្រាជ្ញាថមថយអស់    នេះទោសរបស់អ្នកផឹកស្រា ។

### ខ) ដើរលេងយប់គ្រប់កន្លែង មានទោស ៦ យ៉ាង

១ – អ្នកដែលដើរលេងខុសកាល    មិនបានអភិបាលខ្លួនអាត្មា
២ – អ្នកដើរលេងខុសវេលា    បុត្តភរិយាខានគ្រប់គ្រង ។
៣ – មិនបានថែរក្សាទ្រព្យ    នាំឲ្យអភ័ព្វកើតសៅហ្មង
៤ – គេរង្កៀសនឹងខ្លួនផង    នាំមានសៅហ្មងច្រើនប្រការ ។
៥ – ពាក្យពោលក្លែងបង្កាប់ខ្លួន    ប្រកាន់តាមផ្លូវមានហេតុណា
៦ – មានទោសច្រើនប្រការ    ព្រោះតែអាត្មាដើរលេងយប់ ។

### គ) ដើរមើលល្បែងមហោស្រព មានទោស ៦ យ៉ាង

១ – មានលេងល្បែងរាំទីណា    ទំព្រាប់យាត្រាទៅទីនោះ
២ – នឹកស្មេះស្វែងដើរចំពោះ    ទៅទីណានោះមានចម្រៀង ។
៣ – មានប្រគំក្លួតទីណា    ព្រាប់ចរយាត្រាទៅទីនោះ
៤ – មានរឿងព្រេងស្វែងចំពោះ    ទៅទីណានោះស្តាប់រឿងព្រេង ។
៥ – ចម្រៀងទះដៃទីណា    នោះព្រាប់យាត្រាទៅមើលលេង
៦ – ឃើញស្គរស័ព្ទភ្លេង    គេលេងទីណាទៅទីនោះ ។

### ឃ) លេងល្បែងភ្នាល់ស៊ីសង មានទោស ៦ ប្រការ

១ – អ្នកឈ្នះល្បែងតែងអួសយក ទ្រព្យធនអេមកពីកោតក្រែង
២ – អ្នកលេងចាញ់លង់ក្នុងល្បែង នោះនឹងស្វះស្វែងចងពៀរទុក ។
៣ – វិនាសអស់ទ្រព្យធន អ្នកលេងគង់គន់ឃើញទុក្ខមុខ
៤ – ពាក្យអ្នកលេងគេមិនទុក ចិត្តយកជាមុខស្មរបន្ទាល់ ។
៥ – មិត្រដែលគេមិនលេងល្បែង គេលះបង់ឯងលែងធ្វើស្គាល់
៦ – ពួកអ្នកលេងល្បែងភ្នាល់ លុះដល់ខ្លួនទាល់ហើយលួចលាក់ ។

### ង) សេពគប់តែនឹងមិត្រពាល មានទោស ៦ យ៉ាង

១ – អ្នកលេងល្បែងស៊ីសង ចូលចិត្តតែចងមិត្រពួកល្បែង
២ – អ្នកល្បែងស្រីរកគ្នាឯង ជាអ្នកលេងល្បែងស្រីដូចគ្នា ។
៣ – ពួកអ្នកលេងល្បែងស៊ីផឹក គប់រកប្រមឹកស្រាពាលា
៤ – អ្នកឆបោកដទៃនានា គប់គប់រកគ្នាអ្នកបោកក្លែង ។
៥ – អ្នកក្លែងបោកចំពោះមុខ យកចិត្តដាក់ទុកនឹងគ្នាឯង
៦ – អ្នកឆក់ប្លន់ទ្រព្យស្ដែង រិតរំខ្លះខ្វែងគប់រកគ្នា ។

### ច) ប្រកបខ្លួនក្នុងក្ដីខ្ជិល មានទោស ៦ យ៉ាង

១ – មិនធ្វើការដោយអាងថា ពេលនេះរងាខ្លាំងពេកណាស់
២ – បើថ្ងៃក្ដៅមេឃស្រឡះ ក៏ថាក្ដៅណាស់ត្រូវតែឈប់ ។
៣ – ថាពេលនេះល្ងាចពេកហើយ កុំអាលធ្វើឡើយក្រែងលោយប់
៤ – ថាព្រឹកពេកបង្អង់ឈប់ ចាំល្ងាចព្រលប់សឹមពង្ហើយ ។
៥ – ថាឃ្លានពេកត្រូវស៊ីសិន ឥឡូវចាយឆ្អែតកុំកន់ឡើយ
៦ – ស្រេកពេកចាំផឹកហើយ កុំប្រញាប់ឡើយធ្វើការនេះ ។

ចប់អបាយមុខ ៦ ប្រការប៉ុណ្ណេះ ។

កំពូលកំសត់

លោកហាក់-យេង តែងនិងរៀបរៀង

(តមក)

## បទទី ១១

## សាលី យំសោក

លុះនាងហុតបបរមានកំឡាំងកំហែងហើយ ទើបនាងអង្វរឪពុកឲ្យជូនទៅឯផ្ទះបងចិញ្ចឹមរបស់នាង ព្រោះនាងសន្ទិះក្នុងចិត្តណាស់ ក្រែងមានគ្រោះថ្នាក់ធ្លាក់ដល់សុភិទ្រ ទើបពីរនាក់ឪពុក-នឹងកូនចុះពីលើផ្ទះមកទាំងព្រលឹមស្រាង ៗ ដើរតាមផ្លូវងងឹតឃើញព្រិល ៗ បុប្ផានានារីករាយពេញទាំងសួនត្រជាក់ដោយដំណក់សន្សើម បង្អោនទងមកយ៉ាងគោរពប្រាថ្នាឲ្យនាងបេះ តែនាងបេះតែដើរទៅគ្មានចិត្តគិតដល់ផ្កាទាំងនោះឡើយ ប្រឹងដើរឲ្យលឿនរកបណ្តើរផង ព្រោះគិតដល់បងខ្លាំង ៗ

ដល់មាត់ទ្វារបងផ្ទះសោភិត ក្រឡេកទៅឃើញបង្អួចបន្ទប់សុ-ភិទ្រចំហ នាងក៏ភ័យរន្ធត់រត់យ៉ាងលឿនចូលទៅស្រាប់តែឃើញពនមនុស្សដេកស្តូកស្តឹងផ្កាប់មុខលើប្រឹបថី នាងក៏ធ្លាក់ថ្លើមក្តុក ស្ទើរនឹងខ្យល់ដាច់រលំដួលទៅត្រង់ណោះក៏លុតជង្គង់ចុះ! បើកមុខអ្នកនោះមើល ឪពុកម្ចាស់អើយ! សុភិទ្របងនាងទេតើ នាងក៏លូកដៃឱបបងចិញ្ចឹមរន្ធត់ញាប់ញ័រអស់ទាំងអង្គប្រាណអាក់អួលរំជួលខ្លោចផ្សា ហៀបនឹងទំលាយសង្ខារតាមលោកទៅ រួចក៏ខ្សឹកខ្សួលយំរៀបរាប់ថា :

"ឱបងអើយ ម្ដេចបងមកចាកចោលប្អូនទៅឯកស្រះណោះយ៉ាងនេះ ពីព្រឹកមិញយើងប្រឡែងគ្នាលេងទេតើ  បងបាននិយាយមករកប្អូន បានប្រុងស្ដាប់ពាក្យប្អូនឆ្លើយតបទៅវិញ  ម្ដេចឥឡូវបងបាត់ស្ងាត់មិននិយាយស្ដី  មិនបើកភ្នែកមើលប្អូនផង  មិនញញឹមមករក  ប្អូននិយាយយ៉ាងណាក៏មិនឮ  គួរឬទេតាអើយ !" ។

នាងយំសោកសំរក់ទឹកភ្នែកជាច្រើន  យកដៃអង្រួនខ្លួនបងហើយស្រែកថា "បងអើយបង" ! ក្រោកឡើងកុំសំពត្ដយូរពេក  មិនអាណិតប្អូនផងទេឬ  មិនឮប្អូនហៅទេឬអ្វី  បងស្រដីមករកប្អូនបានមួយម៉ាត់ផងមើល ... ឱ ... ព្រះឥន្ទ្រអើយ  ជួយប្រោសបងខ្ញុំឲ្យរស់ឡើងវិញ ។

អ្នកជិតខាងឮនាងសាលីយំទួញថ្ងូរតាំងព្រលឹមដូច្នោះ  ក៏ទ្រាំមិនបានចុះចាកឋានមក  លុះឃើញភាពគួរអនិច្ចាហើយ  ក៏អត់សង្វេគពុំបានសឹងយំទាំងអស់គ្នា  អាណិតដល់ក្មេងកំព្រាទាំងពីរនាក់  ចំជួយបន់ស្រន់ការក្សទេព្រក្សអ្នកតា  ឲ្យមេត្តាចុះមកជួយស្រោចស្រង់ជីវិតកុមារទាំងពីរនោះផង ។

ចំណែកសោភិតភ្ញាក់ឡើងចេញមកក្រៅ  ឃើញទ្វារចំហក៏គិតភ័យចុះមកដី  ឃើញកូនដេកស្ដូកស្ដឹងដូចកំណាត់ឈើ  ទឹកអាណិតខ្លោចចិត្តអត់ទ្រាំស្រក់ទឹកភ្នែកទើបសំដីនាងសាលីពុំបានកើតទុក្ខប្រាកដខាំមាត់

មិននិយាយស្តី ព្រោះពេលនោះគាត់ហៀបនឹងដាច់ខ្យល់ដែរ ដោយសោយសេ្នហ៍ទឹកឃើញគ្រប់សព្វ ៗ

អ្នកទាំងអស់គ្នានៅទីនោះ ឈរទ្រឹងពុំហ៊ានមាត់ក ខ្លះក៏យកក្រមាជូតទឹកភ្នែកទឹកសំបោរ ញើសតិចៗ មិនឲ្យឮខ្លាំង ម្ល៉ោះហើយអាកាសត្រង់ណោះក៏ស្ងាត់ប្រៀបគួរចម្លែងចិត្ត ឮសូរតែសំឡេងនាងសាលីអណ្តឺតអណ្តកលើទ្រូងបងចិញ្ចឹម យូរៗ ទើបឡើងរៀបពាក្យថា "នេះហេតុតែកម្មផងខ្ញុំ បានជាបងអាយុខ្លីដូច្នេះ នឹកថានឹងបានសុខផងគ្នា ទុកជាកើតទុក្ខក៏ស៊ូទុកជាមួយ ឥឡូវបងមកស្លាប់ចោលខ្ញុំទៅដូច្នេះ សា-លីនឹងរស់តទៅទៀតមិនបានទេ បងកិទ្រអើយ មក...មក យកសាលីទៅជាមួយផង ណាណាកិទ្រណា !!

ហើយនាងក៏បោកខ្លួនលើសពកិទ្រកុមារ ដែលត្រូវអព្រ័នយ៉ាងខ្លាំងដូច្នោះ គួរឲ្យអាសូរណាស់ ស្រាប់តែបើកភ្នែកឡើងញញឹមរកប្អូនរបស់ខ្លួន នាងសាលីឃើញដូច្នោះក៏ត្រេកអរ លោតឱបបងយ៉ាងសប្បាយស្រែកថា "បងដឹងខ្លួនមានជីវិតឡើងវិញហើយ" អ្នកឯទៀតក៏យំឡើងព្រមគ្នាដោយសេចក្តីត្រេកអរ មានមុខញញឹមញញែមមករកគ្នា ៗ

ពេលនោះ ក្តារក្រាលផ្ទះរំពងឡើងដោយសូរជើងដើរ គឺសុវណ្ណ-បុប្ផារត់ចុះមកប្រញាប់ប្រញាល់ សស្ទើតសស្ទក់ដង្ហើររកប្តីនិយាយមិន

បន់ចេញ "អូក! បងអើយ ចោរវាលួចអីវ៉ាន់យើងអស់ពីទូលើងទៅហើយ" រួចក៏គក់ដើមទ្រូងជាទុក្ខ អ្នកឯទៀតជងជូរបោះក៏នាំគ្នាថយចេញទៅ ឯនាងសាលីក៏ភ័យខ្ទត់ដោះដៃពីបង រត់ទៅរកឪពុកនាំគ្នាវិលទៅផ្ទះវិញដោយសេចក្តីកាំចិត្ត ។

ឯសុភិទ្ធទំប្រឹងក្រោកឡើង តែស្រពន់អស់កាំងខ្លួនប៉ុណ្ណាងើបមិនរួច ធ្ងន់ក្បាលធេងធោងចាប់ពើតដូចជាគេជំនីងញញរ ទើបពោលក្អែកមើលបរិវេណខ្លួន ក៏ដឹងថាកំពុងដេកលើពូកគងលើខ្នើយជាច្រើន របស់ទ្រព្យមានដំឡៃរពាយប៉ាយនៅជិតនោះ ទាំងនេះគឺស្នាដៃចោរបន្ទ្រាក់ឡើងតាមបង្អួចចូលទៅវែអីវ៉ាន់ លុះដល់ឮសូរសុភិទ្ធក្រោកទាន់ក៏រត់ត្រង់ដើងទៅ ដល់ឮសូរមនុស្សធ្លាក់ពីលើផ្ទះមកទៀត ក៏ខ្វាយខ្វាតនាំគ្នាគេចទៅតែដៃទទេរៀងខ្លួន ដូចមានដើមផ្កាបាក់ជាឡាក់ហានស្រាប់ ដោយហេតុតែមានពូកខ្នល់ខ្នើយគរក្រោមបង្អួចនោះឯង បានជាសុភិទ្ធរួចជីវិតមិនស្លាប់ក្នុងគ្រានោះ តែអ្នកពលគ្នាមិនបានម៉ែអាថ៌ជាអ្នកបង់សម្លាប់ខ្លួនទេ គេស្មានជាលោតមកដេញចោរលួចនោះឯង ។

បិតាពេញចិត្តណាស់ក៏ចូលទៅត្រកងបី ថើបមុខបបក់ព្រលឹងកូនប្រុសហើយលើកឡើងទៅលើផ្ទះ រកថ្នាំឲ្យកូនផឹករួចដាក់កូនឲ្យដេកស្រួលបួល បានចុះមកនាំប្តីប្រពន្ធសែងរបស់យកទៅទុកកន្លែងដើមវិញ ដល់កូនយំសុំណ្ណាបុប្ផាឲ្យកូនទៅ អស់កំឡាំងមួយម៉ោងស្រែកហៅប្តីឲ្យដាស់

កូនដើមឡើង នឹងប្រើកឲ្យជួយជញ្ជូនអីវ៉ាន់ដាក់លើផ្ទះ តែស្វាមីពុំព្រម ដោយយល់ឃើញថា កូនច្បងរបស់ខ្លួនក៏មិនសូវស្រួល សុវណ្ណបុប្ផានឹង ញ៉ីរសោប់ឆ្លើយមកវិញថា “ល្អហើយបង-យ៉ាងហ្នឹង ផ្តេកផ្តិតឯណាផង បាន បើបងមិនមូលចិត្តគំនិតនឹងខ្ញុំផងនោះ ខ្ញុំចុះចេញពីផ្ទះនេះមួយរំពេច នៅជាមួយគ្នាធ្វើម្តេចបាន បើគេមិនស្តាប់ពាក្យបន្តិចបន្តួចនោះ” ។

សោភិតកើតទោសៈពេញខ្លួនក៏បញ្ជូនពាក្យឲ្យ “អើបើឯងចង់ទៅណាទៅចុះ បងមិនយល់ទាស់ទេ ស្រេចនឹងចិត្តឯង” ។

សុវណ្ណបុប្ផាឮដូច្នោះ ក៏ស្ទុះចូលទៅក្នុងបន្ទប់ភ្លាមទាញដន្ទាប់មក បើកគ្រែយកក្រមួនលាបបបូរមាត់ រួចចាក់ប្រេងលាបសក់ ក្រោយបន្សំញិកញ៉ាក់ធ្វើជាពកូន នឹងចុះពីផ្ទះចេញទៅ. សោភិតឃើញដូច្នោះ ក៏វិលមុខវិលដឹងអ្វី ស្ទុះទៅរាំងមុខប្រពន្ធមិនឲ្យចេញទៅ តែសុវណ្ណ-បុប្ផាប្រាន់ចេញធ្វើមុខមាំ ស្វាមីក៏អង្គុយឱបក្បាលជង្គង់អង្វរកុំឲ្យនាងនឹង ទើបនាងបាត់ធ្វើមុខក្រញូវប្រែជាញញឹមមករក ។

សោភិតលែងនឹកអាណិតកូន ចូលទៅក្នុងបន្ទប់ស្រែកហៅឲ្យចេញមក “នែ ! ឯងឃើញជាម៉ែឯងគេរវល់ទេ បានជាមិនចេញមកជួយធ្វើការនៅសម្ងំដេកដល់ណាទៀត” ។

សុភិទ្រឮដូច្នោះមិននិយាយស្តីថាអ្វី បកភួយចេញពីខ្លួនហើយខំងើបឡើងអង្គុយដោយខំប្រឹងយ៉ាងខ្លាំង ណាអស់កំឡាំងណាឈឺក្បាល

ផង ប្រឹងដើរញញីញញ័រចាកគ្រែមកក្រៅ យកដៃកាន់ទ្វារទ្រជាប់ផ្អែកបង្កាមិនឲ្យដួល ដល់ត្រូវម្ដាយចុងគៀនឲ្យចាប់ៗ ក៏ប្រញិបប្រញាប់ឈានជើងឲ្យវែងៗ តែអនិច្ចាអើយ ជើងទាំងពីរញ័រទទ្រេតទប់ខ្លួនពុំរួច ក៏ស្ទុតដួលចុះស្រិបកណ្ដាលផ្ទះ សុវណ្ណបុប្ផាឃើញដូច្នោះក៏ស្ដីឲ្យថា "ដើរឲ្យលឿនឡើង កុំពុតត្បុតប្រែនពេក ចង់ត្រូវព្រនង់បានដើរឬអ្វី ? ដូចជាគោត្រូវតែគេចាក់ទឹងជន្ទួញបានសមមុខ" ។

សុកិទ្រក៏លើកដៃសំពះម្ដាយចុងអង្វរថា "ឱអ្នកម៉ែខ្ញុំអើយ ! ខ្លួនខ្ញុំនេះពុំមែនខ្ជិលច្រអូសមិនចង់ជួយធ្វើការទេ បើខ្លួនខ្ញុំអាចធ្វើការជូនបានត្រឹមណា ខ្ញុំប៉ុនទឹងធ្វើជូនមិនរួញរាត្រឹមណោះ តែពេលនេះសូមអ្នកសន្ដោសខ្ញុំម្ដងចុះ ព្រោះខ្ញុំអស់កំឡាំងណាស់ មុខជាទឹងធ្លាក់ពីលើផ្ទះនេះជាមិនខាន ដោយឡើងចុះជណ្ដើរមិនកើត កាលបើធ្លាក់ហើយមុខជាទឹងស្លាប់មិនលែង កាលបើខ្ញុំបានស្លាប់ទៅហើយ មុខជាទឹងលំបាកដល់អ្នកម៉ែមិនខានទេ បើដូច្នោះសូមអ្នកម៉ែមេត្តាទុកជីវិតឲ្យខ្ញុំបំរើតទៅទៀតចុះ ។

"អេ៎ ! អញអនុញ្ញាតឲ្យម្ដង តែជួយមើលប្អូនផងកុំឲ្យយំ" ។

សុកិទ្រក៏យកប្អូនមកត រួចខំកកិលចូលទៅកន្លែងខ្លួនវិញ ហើឡើងលើគ្រែដេក តែប្អូនតូចយំកិចកុចពេកណាស់ ក៏ខំលួងលោមឲ្យបាត់យំ "ប្អូនអើយ ! ប្អូនជាទៅកុំយំពេក អាណិតតែបងដែលខំថែទាំប្អូន

ពីទើបនឹងកើតមក ឥឡូវបងអស់កំឡាំងណាស់ នាងនៅឲ្យស្ងៀម ណាប្អូនណា !!!

ទារកនោះហាក់ដូចជាចេះស្តាប់ក៏នៅស្ងៀម យកដៃញាត់មាត់កកែកកមួយសន្ទុះ រួចដេកលក់ដិតបងវាទៅ ។

នៅពេលនោះ អ្នកស្រុកផ្អើលឆោឡោឡើង ព្រោះឃើញខ្មោចតាព្រំនៅចង្ក្រានកណ្តាលផ្លូវ ពួកចៅនាទីក៏មកត្រួតត្រាមើល តែរកមុខអ្នកសម្លាប់មិនឃើញក៏លែងគិតទៅ ចំណែកសំឡាញ់តាព្រំ ក៏មកកៀកកសំឡាញ់យំសោកជាច្រើន រួចអ្នកស្រុកក៏នាំយកខ្មោចតាព្រំទៅដុតជារតាមទំនៀមស្រុក ។

លុះដល់ពេលភ្លឺ សុភិន្ទ្រចេញចាកនិទ្រាបានស្ទាបមុខមាត់ជូរកន្ទួន ទើបងើបឡើងសំអាងកាយស្រួលបួល ចូលទៅផ្ទះបាយរកអ្វីនឹងបរិភោគក៏គ្មាន នឹកឃ្លានណាស់ក៏ចុះពីលើផ្ទះទៅ ក្នុងចិត្តគិតថានឹងទៅបេះត្របែកឯវត្ត ដល់កណ្តាលផ្លូវក៏បានប្រទះនឹងប្អូនចិញ្ចឹម នាងក៏បបួលទៅផ្ទះនាងឯណោះ សុភិន្ទ្រក៏ព្រមទៅដល់ហើយក៏កក់ទាក់សំពះសួរទុក្ខនាងសាលី ដែលមានវាចាមកកាន់ថា

“ កូនអើយ ! ម៉េចឯងអត់ណាស់ ព្រឹក ៗ ចូរមកស្រស់ស្រូបឯណោះមករួចសឹមទៅសាលា ” បែរទៅពួកទាសីបង្គាប់ឲ្យរៀបបាយទឹកមក សាលីអង្គុយចាំបំរើបង រួចសាកសួរអំពីហេតុដែលបងធ្លាក់ពីលើផ្ទះ

មកដេកលើពូក ដល់ដំណើរឿងកាំសេតូត្រប់ហើយ នាងក៏ស្រែកឡើងថា "តុទោអើយ ! នេះបជាមិនអាណិតដល់ចិត្តសាលីសោះតែម្តង ម៉េតាន ពួកជនមុខជាស្លាប់ពានឃើញមុខគ្នាមិនលែង តែហេតុផលបុណ្យសាលី បានជាមិនអី ! បងសុកិន្ទ្រអើយ ពីថ្ងៃនេះទៅ ប្ដូបងសុទ្យោឲ្យប្អូនជា ទុកជាបងពិបាកយ៉ាងណា ក៏មិនសម្លាប់ខ្លួនដែរ ណាកិន្ទ្រណា !!! ។

"មិនអីទេប្អូន បងសន្យាឲ្យ" ។

"ឲ្យតែដូចពាក្យសន្យាណា !! ។

នៅវេលានោះ បិតានាងសាលីបានប្រើឲ្យមនុស្សក្នុងផ្ទះជាំជាំរេប ឲ្យសិតមកឲ្យសុកិន្ទ្រ ដឹករួបហើយ ក៏មានកំលាំងពលំដូចដើមវិញ លើកដៃសំពះ អរគុណ ទើបលាវិលមកសំណាក់ការគ្នាវិញ តាប់ធ្វើការ ដណ្តាំស្ដូដូចមុនៗ ។

## បន្ទី ១៤

# ភ្នំពេញ

ពន្លឺភ្លើងអគ្គិសនីចុះព្រោងព្រាតចិញ្ចែងដូចវេលាថ្ងៃ បំភ្លឺផ្លែដែល អ្នកដើរទៅដោយរថយន្តត្រប់ខែប ។ ពោបក្រយាន ទឹងត្រីបក្រយាន ទៀលធ្លាក់ចុះឡើងមិនចេះអស់ លើចិញ្ចើមថ្នល់ធំ មានមនុស្សកុះករដើរ ហែកាមគ្នាមិនចេះអាក់ មើលពីចម្ងាយឃើញតែលេកក្បាលខ្មៅគ្រាំ

គគ្រឹន ហាក់ដូចជាមានបុណ្យទានអ្វីអឹកធឹក តាមដោយពិតនោះ ក្រុងភ្នំពេញដូចជាមានបុណ្យមួយដ៏ចំឡែកដល់ភ្នែកអ្នកនៅស្រុកក្រៅ ។

មានកុមារម្នាក់ស្លៀកពាក់បែបជាអ្នកខេត្តក្រៅ ដើរជិតឪពុករបស់ខ្លួនទឹកស្ញើចក្នុងចិត្តណាស់មាត់ថា "ស្រុកអីរុងរឿងម៉្លេះមនុស្សអើមនុស្ស" ដល់ដើរមួយស្របក់ទៅចង់វិលមុខ ទើបគេចូលក្នុងហាងចិនគន់មើលទំនិញគ្រប់មុខដែលរៀបជាលំដាប់លំដោយក្នុងទូកញ្ចក់ មានរបស់ចំឡែកៗ ប្លែកភ្នែកគួរឲ្យគន់មើលគួរឲ្យទស្សនា បិតាកុមារនោះឃើញក្របូបស្បែកដាក់លុយនឹកចង់បាន ទើបសួរដំឡៃដល់ចិនអ្នកលក់ក្នុងចៅចៀនកាយចៀកមើលមុខឃើញថា អ្នកស្រែកនិយាយបែបមើលងាយ "ថ្លៃណាស់កុំពាល់" ។

"ថ្លៃណាស់ តើប៉ុន្មានទៅ?

"អាហ្នឹងថ្លៃ ៩ រៀល ស្បែកល្អផ្ញើពីស្រុកបារាំងមក" ។

ចួនជានៅជិតនោះមានខ្មែរគ្នាឯង គេជួយនិយាយឡើងថា "នេះឃើញតែគ្នាមកពីស្រុកក្រៅហ្នឹង បេះតែដំឡើងថ្លៃទៅតាមចិត្ត ក្របូបបែបនេះ គេទិញតែ ១ រៀលទេតើ" ។

អាចិនខាតណាស់និយាយអ៊ូជាភាសាវ៉ាំ ហើយយកក្របូបស្បែកដាក់កន្លែងដដែលវិញ ។

ឪពុកនឹងកូនពីរនាក់ ក៏ចេញពីកន្លែងនោះដើរតទៅទៀត លុះ

បត់ចុះបត់ឡើងក៏បានដល់ភាពយន្ត "អិចសែលស៊ីយ៉ូរ" ដែលមាន កណ្ដឹងរោទ៍លាន់ឆ្ងាយ ជាសញ្ញាថាជិតដល់ម៉ោងហើយ នៅមាត់បង្អួច កន្លែងលក់សំបុត្រ មនុស្សកកដណ្ដើមគ្នាទិញកន្លែងអង្គុយមើល ខាង ក្រោយអ្នកទាំងនុះ ពួកនារីឈររៀបចូក ពាក់អាវទាន់សម័យផ្សាយ ទឹកអប់ក្រអូបសាយ អ្នកចម្ងាយទាំងពីរនាក់នាំគ្នាឈរមើលភាំងស្មារតី ដល់គេចូលទៅក្នុងអស់ទៅ ក៏នឹកព្រួចចង់មើលនឹងគេ ទើបទិញសំ- បុត្រហើយដើរចូលទៅ ។

វេលាកុនរៀបលេង ប្អូនជាកុមារនោះងាកមុខទៅក្រោយមើលគេ ឯង ស្រាប់តែឃើញស្ត្រីកណ្ដាលអាយុម្នាក់ ស្លៀកពាក់ហ៊ុំហាសុទ្ធតែ ព្រែមានមុខស្រពោនបន្តិច នាំឲ្យនឹកដល់ភាពមាតារបស់ខ្លួន ក៏នឹកអរ ព្រួចចំងើបឈរឡើងនឹងបក់ដៃហៅ បើជាម្ដាយរបស់ខ្លួនមែន នោះ មុខជានឹងស្គាល់កូនមិនលែងទេ នៅវេលានោះស្រាប់តែភ្លើងរលត់ភ្លឹប នាំឲ្យកុមារសោប់សល់ក្នុងចិត្តពន់ប្រមាណ ព្រោះខានបានពិនិត្យមើល ឲ្យច្បាស់លាស់, តើជាម្ដាយរបស់ខ្លួនឬមិនមែន ។

ដល់កុនចេញមក អ្នកស្រុកក្រៅទាំងពីរនាក់ ក៏ពុំជាចំមាត់សរ- សើរឆ្ងល់នឹងស្រមោលចេះនិយាយស្ដី ដូចជាមនុស្សមែនទែន ឆ្ងល់ទីង ធម្មជាតិយ៉ាងណា ក៏ឃើញស្រស់ៗ ទីកន្លែងយ៉ាងនោះ ឮសូរយ៉ាងណា ក៏ឮដូច្នោះមិនមានខ្លៀងខ្លងទំនងដើម តែភាសានិយាយនោះជាភាសា

-បាក់ង      កុមារទទួលភារៈនឹងបកប្រែចេញមកជាខេមរភាសាឲ្យឪពុក ស្តាប់ទាំងអ្នកអង្គុយជិតនោះប្លែកគ្រប់គ្នា ពីព្រោះកុមារនោះ ដូចអ្នកមើលបានស្មានក្នុងចិត្តថាដូចអ្នកណាហើយ គឺសុភិទ្រនោះឯង ដែលសោភិតជាឪពុកនាំមកទីក្រុង ដើម្បីនឹងប្រឡងយកបដិញ្ញាណ ។

លុះកាលយន្តរលត់ពីផ្ទាំងសំពត់សហើយ មានភ្លើងភ្លឺចិញ្ចែងឡើង ចិត្តសុភិទ្រក៏អណ្តែតអណ្តូងព្រឺព្រួច ចាំងើបឡើងជាប្រញាប់រំពៃមើលមាតារបស់ខ្លួន តែគួរឲ្យខ្មាញ់ណាស់ត្រូវគេច្រានចុះឡើង ដោយតាមគេរេលទៅមុខ ៗ ដល់ចេញមកខាងក្រៅ ស្រាប់តែឃើញស្ត្រីកណ្តាលអាយុនោះជិះឡានចេញផុតទៅហើយ សុភិទ្រខ្មាញ់ណាស់យកដៃបោចសក់ក្បាលទឹកចង់យំនៅមុខគេរាល់គ្នា ស្តាយមិនបានចេញមកឲ្យទាន់ទីងគន់មើលថាជាម្តាយរបស់ខ្លួនឬពុំមែន ។

លុះវិលមកទីសំណាក់វិញ ក៏អង្គុយសំកុកសញ្ជឹងសញ្ជប់តែម្នាក់ឯង ម្តាយមីងសាកសួរយ៉ាងណាក៏ពុំបានឆ្លើយឲ្យពិស្តារ ព្រោះត្រូវការនៅស្ងាត់តែម្នាក់ឯង ដើម្បីនឹងរឭកដល់អនាគតរបស់ខ្លួន នឹងទឹកដល់ហេតុការណ៍អម្បាញ់មិញនេះឯង ។ ម្តាយមីង មាឌតូចល្មមមុខក្រៀមក្រស់តែក្នុងទ្រង់ស្រគាប់ មិនជាអ្នកក្លៀវក្លាហាក់ដូចជារូបសិទ្ធចេះនិយាយទឹកស្មានថាក្មួយអស់កំឡាំងមកពីដើរ ក៏រៀបកន្ទេលខ្នើយចងមុងឲ្យក្មួយដេកទៅ ។

យប់នោះ សុភិក្ខុដេកក្រលក់ប្រែប្រួលចុះឡើង នឹកដល់សេចក្តីកំសត់របស់ខ្លួន ក៏ជោរជល់ទឹកភ្នែកជោកខ្នើយ នឹកអំពីប៉ែកចាកមាតា អំពីវេទនានៅម៉ឺនម្នាក់ឯងទៀបទឹងធ្វើការក្នុងផ្ទះ អំពីឃើញមុខម្តាយប្រហាក់ប្រហែល ហើយមិនបានស្ទុះទៅមើលឲ្យជាក់នឹងភ្នែក នឹកអំពីខ្លួនរៀបទៅប្រឡងមិនដឹងជាយ៉ាងណា ឮសូរសត្វជីងចក់យំកណ្តាលយប់ស្ងាត់រងស្រណោះដល់រូបគ្នា បែរមើលប៉ារបស់ខ្លួនកំពុងស្រមុកខៗ ដល់នាឡិកាវាយម៉ោង ១១ ក៏កាត់ចិត្តលែងនឹកនារឿងអ្វីៗ មិនយូរប៉ុន្មានក៏លក់ស៊ប់ទៅ ។

លុះព្រឹកព្រាងឡើងកាលណា ក៏ក្រោកបាតដំណេកសំអាងតាក់តែងខ្លួនស្រស់ស្រូបហើយក៏កាន់ក្រដាសមួយរមូរ ក្រដាសផ្តិតមួយសន្លឹកព្រមទាំងបន្ទាត់និងឧបករណ៍ឯទៀតៗ សោភិតក៏ជូនកូនត្រសង់តាមផ្លូវទៅៗ តាមកុមារឯទៀតៗដែលប្រជុំគ្នាពីខេត្តក្រៅមកនៅសាលាប្រៀងស្តាបជាំង នាំគ្នាឈរពេញតែចំពោះមុខ ដណ្តើមគ្នាមើលឈ្មោះដែលបិទនៅនឹងកំពែងសាលា ដើម្បីឲ្យដឹងថាគេខ្លួនត្រូវចូលទៅអង្គុយថ្នាក់ណា ។

( មានត )

# ប្រជុំសុភាសិតខ្មែរតាមលំដាប់អក្សរ

## ហង្សគិតពន្ធមន្ត្រី ញ៉ុក-ថែម  រៀបរៀងនិងរួបរួម

### អក្សរ ម (តមកពីខាងមុខ)

◎ មានគំនិតឥតកំណើត ។

◎ មានធនប្រពន្ធមិនក្រ, មានដីសមិនក្រក្តារខៀន មានរបៀនមិនក្របស់ ។

◎ មាន់ណាខ្ទត, មាន់នោះពង ។

◎ មានះបាត់មិត្តឥតអ្នកជាដៅ, ក្រេវក្រោធហោរហៅរមែងបាត់អង្គ ។

◎ មានសម្រាមទើបផ្កែកផុះ ។

◎ មានទុក្ខមហាក្សត្រ, មានទុក្ខទៅវត្ត, មានទុក្ខស្រីមានរូប ។

◎ មានប្រឡាយទើបទឹកហូរ ។

◎ មាន់ពងលើជង្រុកស្រូវ ។

◎ មាន់ព្រៃកំពាយមាន់ស្រុក ។

◎ មិនជឿពាក្យស្រីអស់ស្រូវពូជ ។

◎ មឹះៗ កេះឆ្នាំងបាយក្ដុះ ។

◎ មុខថ្កែ ស្រីដំពៅ ។

៙ មេម៉ាយកូន ១ ដូចព្រហ្មចារី, មេម៉ាយកូន ៣ ដូចស្រីសាវកែ ៗ

៙ ម្ទៅៗ ទៅយកឯដ៏ព្ទៅមកត្បៀតក្បៀក ៗ

៙ ម្ទៅៗ ទៅយកស្ករផ្ញើនឹងស្រមោច ៗ

## អក្សរ យ

៙ យល់ញាតិឃ្លាតច្បាប់ ៗ

៙ យល់តូច កុំគាលខំ, ទោះយល់ធំកុំគាលស្រាយ ៗ

## អក្សរ រ

៙ រទេះបាក់មិនគិត ទៅគិតឯគោលួចដាំង ៗ

៙ រទេះបាក់ត្រង់ណា, ល្អិតស្មៅត្រង់ណោះ ៗ

៙ រើសពោសដូចស្រុកឥតស្ដេច ៗ

៙ របស់ព្រះ, បូជាព្រះ ៗ

៙ រនាបបាក់គ្រាន់នឹងជួស, តែមាត់រហូសកំពប់ប្រាក់ ៗ

៙ រហ័សតែមាត់, ត្រគាតស្ទាប់ស្ដូក ៗ

៙ រកទុសប្រទះឈើឆាប់ ៗ

៙ រស់នៅថាអាក្រក់, ស្លាប់បាត់មុខថាល្អ ៗ

៙ រើសដៃផ្ទៃផ្អែត ៗ

៙ ឫក្សជតា ក្រៃណានឹងទទ្យាកំណើត ៗ

៙ ឫស្សីព្រៃ ដើមទៅផ្សេងថ្នាំង, ប្អូនត្រឡាំងទៅផ្សេងចិត្ត ៗ

៙ រេបទាំងលើទាំងក្រោមដូចក្បាលកិន ។

៙ រោចគល់ រញ្ជួយដល់ចុង ។

## អក្សរ ល

៙ លាក់តែមុខដូចពង្រល ។

៙ លិចសមលោក, ផល់កំប៉ូតសមគោង ។

៙ ល្អផ្កាឲ្យមើលខ្យល់, ក្ដីពុំយល់កុំអាលក្រោធ ។

៙ លូកប្រហុកឲ្យកប់ដល់ក្លៀក ។

៙ លួចគេទម្លាប់ដៃ, ដេកថ្ងៃទម្លាប់ភ្នែក ។

៙ លើកស្លាបផ្ការក្អែក ។

៙ លេងនឹងក្មេងវាអប្បយស, លេងនឹងពស់វាខាំដៃ, លេងនឹងចាស់វាចង្រៃ ។

## អក្សរ វ

៙ វៃក្អមប្រហុកអស់ ។

៙ វាយឲ្យយំហើយ, ទើបបញ្ចុកចេកឲ្យ ។

## អក្សរ ស

៙ សត្វក្ងែកស្លាប់ដោយសារប្រើស ។

៙ សង់ផ្ទះតាមចិត្តអ្នកនៅ ។

៙ សប្បុរសពេកចាញ់ធន, នារីដំនាចាញ់ឥន្ទ្រិយ៍ ។

៙ សាច់មិនបានស៊ី, យកឆ្អឹងព្យួរក ។

៙ សាបមួយដៃ, ប្រៃមួយចំប ។

៙ ស៊ីច្រើនៗ ជុះ, លេងច្រើនៗ ឈ្លោះ, ដេកច្រើនៗ ខ្ជិល ។

៙ ស៊ីនឹងអ្នកណា, យកអាសាអ្នកនោះ ។

៙ ស៊ីបាយដេក បាយសរសើរ, ស៊ីបាយដើរបាយប្រទេចផ្តាសា ។

៙ ស៊ីបាយនឹងពន្លឺទៀន, និយាយនឹងមនុស្សមានរបៀប សប្បាយស្តាប់, ស៊ីបាយនឹងពន្លឺខ្យល់ និយាយនឹងមនុស្សកំហល់, ប៉ុនគេយកអង្រែបុកដើមទ្រូង ។

៙ ស៊ីសាច់ជាប់មេត្តា, សេពសុរាគ្មានពាក្យទៀង ។

៙ សឹកដល់កុំអាលធ្លាយ, ពាក្យពីធ្លាយកុំអាលយក ។

៙ សូវកាប់កុំឲ្យជន្ទ, សូវដេររមេដកចងជួរ កុំឲ្យជាប់នៃរុយ ។

៙ សូវបួលកុំឲ្យពេញ, សូវទិញកុំឲ្យដូរ ។

៙ សូវខ្វល់គិតបារ, កុំឲ្យខ្វល់គិតកញ្ញើ ។

៙ សូវបង់ប្រាក់មួយថង់ កុំឲ្យបង់ពាក្យសត្យ ។

៙ សូវបែកក្បាលកុំឲ្យបែកធ្នាំង, សូវបែកចង្កាជាំងកុំឲ្យស្រីមើលងាយ ។

៙ សូវឲ្យក្រពើលេប កុំឲ្យបង្ហាប្រប៉ិច ។

៙ សូវឲ្យសាច់កុំបង្ហាញព្រៃ ។

៙ សូវយកសំផឹងធ្វើប្រពន្ធ, កុំឲ្យតែប្រពន្ធធ្វើសំផឹង ។

៙ សូវស្ដួចកុំឲ្យដាច់, គិតការពុំទាន់ស្រេចកុំអាលរន្ធត់ ។

៙ សូវស្លាប់ប៉ា កុំឲ្យស្លាប់មេ លង់ទូកកណ្ដាលទន្លេ កុំឲ្យតែភ្លើងឆេះផ្ទះ ។

៙ សំណាបយោងដី, ស្រីយោងប្រុស ។

៙ ស្នាព្រាន ចម្បាំងស្មោង, ស្បាងឆ្នាំ, ក្រមុំស្រុកចម្ការ, ព្រាបង់ពេជតា, ស្រាស្រុកពោធិ៍សាត់ ។

៙ សម្លមិនឆ្ងាញ់ឲ្យតែក្ដៅ, ប្រពន្ធខ្មៅឲ្យតែនៅក្មេង ។

៙ ស្លឲ្យសាប, អង្គុយឲ្យទាប, ប្រាជ្ញាឲ្យវែង, សំដីឲ្យខ្ពស់ ។

៙ សំឡេងប្រាប់ភាសា, កិរិយាប្រាប់មារយាទ ។

៙ ស្លសាបកុក, សាច់ម៉ាជាប្រហុក, ពោះម៉ាជាបន្លែ ។

៙ ស្លឹកឈើជ្រុះមិនដែលឆ្ងាយពីគល់ ។

៙ ស្លឹកឈើឥតកំរើក, បើក្រែកផ្សៀតខ្យល់បក់ ។

៙ ស្លូតស្លាប់ វៀចវេរមានភ័ព្វ, អាយុយឺនយូរ ។

៙ ស្លៀកស្បង់មិនកោរសក់ ធុះកញ្ចក់ធ្មបនេត្រា ។

៙ ស្វាមិនបង់បៀម, សៀមមិនបង់ក្បួន, យួនមិនបង់ពុក, ខ្មែរស៊ុតទ្រុតមិនបង់ថៃបូរ ។

៙ ស្វែងរៀនគេប្រាប់, ពុំស្មើចិត្តជា ។

◎ ស្នេហ៍មិនស្មើស្និទ្ធ ។

◎ ស្អប់កុំឲ្យបាញ់, ស្រឡាញ់កុំឲ្យខ្ចី ។

◎ ស្រឡាញ់ខ្លួនឲ្យស្ងួនបំណើ, ស្រឡាញ់ប្ដីឲ្យស្ងួនចិត្ត ។

◎ ស្រឡាញ់ពេញប្រាស, ស្អប់ជំពប់លើ ។

◎ ស្រម៉មិនដែលទុំ, ក្រមុំមិនដែលស្លូត, បង្គួតមិនដែលត្រង់, កំពង់មិនដែលស្ងាត់, មាត់មិនដែលស្ងៀម ។

◎ ស្រឡាញ់ផ្លែឲ្យថែគល់ ។

◎ ស្រឡាញ់ម៉ែ ឲ្យថែកូន ។

◎ ស្រឡាញ់កុំឲ្យទៅញឹកៗ ដល់លើកសំពះតាមួនៗ ។

◎ ស្រីមួយដូចក្របីមួយដើម ។

◎ ស្រើបតាមផ្គរ, អរតាមភ្លៀង ។

## អក្សរ ហ

◎ ហុតសម្លសំឡឹងកាក, ហូតប៉ាក់ក្រាកសំឡឹងព្រោយ ។

◎ ហុចអំបោះមិនឲ្យស្រណោះដៃ, ។

◎ ហេតុមិនស្រឡាញ់សឹងថាធ្លាយ, ទុកបែកសំពៅធ្លាយសោក ដល់លក្ខាធាយ, ស្រឡាញ់ហើយទើបទៅបាន ។

## អក្សរ អ

◎ អង្ករមួយកាប់, បបរមួយថ្លាង ។

- អក្សរជាត្រី, សំដីជាឯក, លេខជាទោ ។
- អណ្ដើកនៅផើង, តាំអីក្ដក់ហៅក្ដែ ឬអណ្ដើកនៅផើង, តាំអីរកក្ដែ ។
- អណ្ដាតជាភាតកន្ទង, បង់ទ្រព្យធនផងពីព្រោះអណ្ដាត ។
- អត់មិនអត់យកកោលអន្ទាក់ ។
- អន្ទង់ឲ្យទុនផុក, រីឯកុកឲ្យទុនត្រពាំង, ។
- អាក្រក់តែរូប, ម្ហូបគេល្អ, ល្អតែរូបម្ហូបមិនកើត ។
- អាស្វាមិនទាន់ស្គាល់ព្រនង់ ។
- អាវែកគេស៊ីក្រោមក្អែក, អាវែកមិនដឹងខ្លួន ។
- ឥតដំបៅហៅជម្ងឺ, ដំបៅមិនឈឺយកឈើចាក់ ។
- ឥតទ្រព្យអប្បប្រាជ្ញា ។
- អឹមជាងអៀម, ស្ងៀមជាងស្រដី ។
- អូសទូកកុំឲ្យល្អាន, ចាប់ត្រីបានកុំឲ្យល្អក់ទឹក ឬអូសទូកកុំឲ្យល្អាន, ទឹកថ្លាសោតកុំឲ្យល្អក់ ។
- អួសស្រមាស់ប្រទះពាក្យ ។
- អួតបេះរបេះក្បាប ។
- ឲ្យកូនគ្រាប់ពុតកង់, វិលត្រប់អង្គត្រូវត្រប់ប្រាណ ។
- អំបែងបែករកអំបែងណាដូច ។

ចប់តែប៉ុណ្ណេះ ។

## ច្បាប់ក្រមបរិយាយ

# លោកញុំក-នូ គ្រូបង្រៀនជំនួយ

### នៅវិទ្យាល័យស៊ីសុវត្ថិ

(តមក)

ពាក្យនេះ ត្រូវញែកជា ៣ វគ្គ តាមលំដាប់ ៗ វគ្គខាងដើមគឺ "មួយចង់ក្តីច្បាប់ ឲ្យបានខ្លួនគាប់ នៅនាលោកិយ" បានសេចក្តីថា មាតាបិតាមានប្រាថ្នា ចង់ឲ្យកូនចេះដឹងច្បាប់សំរាប់ស្រុក និងទំនៀមទម្លាប់ប្រពៃណី ដើម្បីដាក់ខ្លួនឲ្យនៅក្នុងសេចក្តីសុចរិតនេះ ១, និងបានជាទីពឹងទីបង្អែករបស់អ្នកទាំងពួង ដែលត្រូវការនេះ ២, នឹងនាំខ្លួនឲ្យបានគាប់ចិត្តនៃអ្នកដទៃ ជាទីគោរពកោតក្រែងរបស់ជនានុជន នៅនាលោកិយនេះ ដោយកំឡាំងវិទ្យាសាស្ត្រនេះ ៣, ទាំង ៣ បទនេះគឺក្នុងវគ្គទីបឋម ព្រោះអ្នកទាំងពួងដែលមានកិច្ចការរវល់ផ្សេងៗ រមែងត្រូវការរកអ្នកចេះច្បាប់ទំលាប់ទំនៀមទុកដូចជាក្បួនខ្នាតនិមួយៗ, ហើយកាលគ្នាបានឃើញមក ហើយក្នុងប្រទេសមួយៗ អ្នកស្រុកដែលដូចមានទុក្ខ ពុំសុខចិត្តទាស់ទែងខ្វែងគំនិតគ្នា គេតែងប្តឹងតវ៉ាដល់ក្រសួងតុលាការ សូមឲ្យអស់លោកចៅក្រម ដែលជាអ្នកចេះច្បាប់ជំនុំជំរះរកសេចក្តីខុសត្រូវកាត់សេចក្តីឲ្យ, រួមដូចមានច្បាប់បុណ្យទានផ្សេងៗ មានច្បាប់ឈាបនកិច្ច, បញ្ចុះធាតុ បញ្ចុះសីមា, ច្បាប់មង្គលការអាពាហ៍ពិពាហ៍ជា

ដើម ៗ ល ៗ អ្នកទាំងឡាយតែងតែរកពឹងអ្នកបេះក្បួនខ្នាត ចាំទម្លាប់ទំនៀម មកជាអធិបតីចាត់ការ ឲ្យត្រឹមត្រូវឲ្យ, បុគ្គលដែលបេះដំពូកនេះ មានបោរាណាចារ្យនឹងអ្នកផ្សំពោមហាជាដើម ៗ

វគ្គទី ២ "មួយចង់ប្រាជ្ញា មិនឲ្យអប្រិយ" បានសេចក្តីថា មនុស្សខ្លះមានចិត្តប្រាថ្នា ចង់បានចំណេះវិជ្ជាផ្សេងៗ ជាកំរូនប្រយោជន៍ដើម្បីនឹងតាំងខ្លួន ជាបណ្ឌិតជាតិជាអ្នកឈ្លាសវាងវៃ មិនឲ្យថយថោកដោយល្ងង់ខ្លៅ ព្រោះយល់បានថា ធម្មតាអ្នកអាប់ឥតប្រាជ្ញា មានអាយុរស់នៅមិនរុងរឿង ម្ល៉ោះហើយគេខំសង្វាតឃ្មាតខ្មីព្យាយាមរៀនសូត្រឥតខ្ជិលច្រអូសឡើយ ខំរៀនលុះត្រាតែសំរេចការដូចបំណង ៗ

តែវិជ្ជាត្រង់ណេះ លោកសំដៅយកវិជ្ជាល្អៗ ដូចយ៉ាងអក្សរសាស្ត្រ ប្តូបង្កើតប្រដាប់ប្រដាប្រើប្រាស់ បេះធ្វើគ្រឿងយន្តផ្សេងៗ ៗ ល ៗ នេះទើបរាប់ជាវិជ្ជាល្អ, បើដើរស្វែងរៀនខាងវិជ្ជាមន្តធ្វើបោរលួចប្លន់គេ ជាវិជ្ជាមានទោស នោះលោកពុំរាប់ចូលក្នុងវិជ្ជាប្រសើរទេ ៗ

វគ្គទី ៣ គឺ "មួយចង់បារមី នាំញាតិទាំងឡាយ" បានសេចក្តីថា មនុស្សជំពូកនេះ ចង់បាននូវបារមី គឺគុណធម៌ល្អ ដែលខ្លួនបំពេញឲ្យដល់ត្រើយ គឺសេចក្តីសុខ ហៅថាបារមីមានទានសីលជាដើម មានមេត្តានឹងឧបេក្ខាជាបរិយោសាន, បុគ្គលទាំងនេះ គឺភិក្ខុសាមណេរនិងឧបាសកឧបាសិកា ជាអ្នករក្សាសីលឲ្យមានជាដើម លោកអាចដឹក

នាំញាតិសាលោហិត មានមាតាបិតាជាដើម ញុំាងចិត្តឲ្យចុះទៅកាន់ធម៌របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលត្រាស់សំដែងនូវព្រះបរមទុកទ ដឹកសត្វកាត់វដ្តសង្សារ ឲ្យរួចចាកអបាយភូមិទាំង ៤ ដាក់ដល់ត្រើយគឺព្រះនិព្វាន ។

ទី៨- ឱអស់សាមណេរ កុំធ្វើដែលដែរ ត្រង់ក្តី ពាយផ្ដាយ លំនុតបំរើ អ្នកជាធាជ្យាយ ជូនបុណ្យ ទៅម្តាយ អាពុកឪពៃ ។

គ្រូដាស់តឿនសិស្សានុសិស្សកាលបួសហើយថា ចូរអ្នកកុំធ្វើ ដូចកាលដែលអ្នកនៅជាគ្រហស្ថ បួសហើយកុំធ្វើបែហាសក្មេងខ្លួនឲ្យដឹងថាខ្លួនសព្វថ្ងៃនេះបួសហើយ, ចូរអ្នកចាំថាកាលមិនទាន់បួស អ្នកមានបញ្ញាប់ទម្លាប់ទំនៀម សំកប់គ្រហស្ថ ដែលអ្នកត្រូវប្រតិបត្តិជាប្រក្រតី ឥឡូវមាតាបិតាយកអ្នកមកបន្ទំជាសាមណេរហើយត្រូវអ្នកប្រព្រឹត្តតាមសិក្ខាវិន័យឲ្យត្រឹមត្រូវវិញ ។

ចូរអ្នក "លំនុតបំរើ អ្នកជាបាធ្យាយ ជូនបុណ្យទៅម្តាយ អាពុកឪពៃ" បានសេចក្តីថា ឲ្យសាមណេរនោះ យកចិត្តទុកដាក់ បំរើគ្រូបាធ្យាយ អាចារ្យឧបជ្ឈាយ៍ ដ្បិតកិច្ចបំរើឧបជ្ឈាយ៍អាចារ្យនេះ ជាបុញ្ញាកស័មួយដ៏ឧត្តម ដើម្បីយកបុណ្យនេះ ឧទ្ទិសបញ្ជូនទៅមាតាបិតា រៀងកល់ខ្លួន ។

ឯកិច្ចបំរើគ្រូឧបជ្ឈាយ៍នោះ គឺឲ្យទេនផ្គត់ផ្គង់ទឹកស្រង់នូវទឹកឆាន់ បោសប្រាសទីសេនាសនៈ គោរពប្រណិប័តន៍ក្រាបសំពះជានិច្ច, គ្រាបើលោកមានរោគាពាធ ត្រូវរកពេទ្យមកផ្សំថ្នាំព្យាជម្ងឺ ។ល។ នេះទើបហៅថាជាសិស្សមានកតញ្ញូ ព្យាយាមធ្វើវត្តប្រណិប័តន៍គ្រូបាធ្យាយ ។

តែបើវេលាស្រេចកិច្ចទាំងឡាយនេះហើយ ត្រូវមានកិច្ចតទៅទៀត ។

សង្កាត់សូត្ររៀន កុំធ្វើអៀនប្រៀន ក្នុងចិត្តសព្វថ្ងៃ លំឱនបម្រើ ផ្ចង់ដោយហឫទ័យ ចាំរម្លៃៗ ក្តីច្បាប់កុំបីបង់ ។

ជាឲ្យមានវិរិយៈ ខំរៀនសូត្រឲ្យណាស់ផង "កុំធ្វើអៀនប្រៀនក្នុងចិត្តសព្វថ្ងៃ" ពាក្យនេះប្រាប់ថា ធម្មតាអ្នករៀន ត្រូវកុំឲ្យអៀមអៀនស្ទើរស្ទើមិនស្ទីនោះ កុំឲ្យខ្មាស់អៀនខ្ទីនគ្រូបាធ្យាយឡើយ បើសិស្សឯណាខ្មាស់គ្រូហើយ សិស្សនោះក៏មិនបានចេះដឹងណាស់ ។ បទនេះត្រូវនឹងភាសិតបុរាណមួយថា "ខ្មាស់ភរិយាឥតកូន ខ្មាស់គ្រូឥតចំណេះ" ធ្វើជាអ្នករៀនហើយ ត្រូវតែឲ្យឈ្លះឈ្លាយ ឧស្សាហ៍សួរដណ្តឹងគ្រូបាធ្យាយ អំពីកិច្ចការដែលខ្លួនពុំយល់ សំពះសូមឲ្យលោកគ្រូ អធិប្បាយស្រាយកែបញ្ហាឯណាដែលខ្លួនពុំគិតនោះ មិនតែប៉ុណ្ណោះឡើយ ត្រូវអាចហានសាកសួរអ្នកដទៃផងទៀត ដែលគេមានចំណេះ

ជាជាងខ្លួន កុំគប្បីអៀនអន់ យ៉ាងនេះទើបបានចំរើនបានចំណេះច្រើន ស្ទាត់ នេះហៅថាមិនអៀនប្រៀន ក្នុងការរៀនសូត្រ ។

រីឯកិច្ចគឺ "លំឱនបំរើ ផ្គាប់ដោយហឫទ័យ បារម្ភមៃៗ ក្ដីច្បាប់កុំបីបង់" ជាពិតមែនជាយើងរវល់ខ្វល់នឹងរៀនសូត្រហើយ តែយើងមិនត្រូវលះបង់ចោលច្បាប់គឺសិក្ខាវិន័យ ដែលជាធម្មត្រូវសំរាប់សមណៈ ត្រូវឲ្យមានចិត្តនោះនឹកមើរតែប្រុងប្រយ័ត្ន បំពេញកិច្ចទាំងពីរឲ្យបរិបូណ៌ហោង ។

ទី៩ ច្បាប់នេះសោភណា ទូន្មានអាត្មា ដោយនូវក្រិត្យសង្ឃ ត្រង់ណាហៅច្បាប់ កាន់ខ្ជាប់កុំបីបង់ ចំណោរទៅលង់ ខ្លួនបានជាធំ ។

ច្បាប់នេះហើយ សម្រាប់ឲ្យអ្នកប្រៀនប្រដៅខ្លួនឲ្យបានល្អ ផ្សិតធម្មតាអ្នកបួសត្រូវកាន់ក្រិត្យវិន័យសង្ឃ ឲ្យជាវរៈម៉ាំទាំ តាមលំដាប់នៃកិច្ច ដូចពាក្យថា "ត្រង់ណាហៅច្បាប់ កាន់ខ្ជាប់កុំបីបង់" ឲ្យយកចិត្តទុកដាក់រក្សាសីលឲ្យជាប់ កុំឲ្យពព្រុសពាលសៅហ្មងទៅបានដោយសេចក្ដីប្រមាទ បំពេញកិច្ចដែលគួរធ្វើ នេះជាឧបាយនៃបញ្ញា ។ បើសាមណេរឯណាមានសេចក្ដីព្យាយាមកាន់ច្បាប់ខ្ជាប់ខ្ជួននូវក្រិត្យវិន័យ ពុំឲ្យមានហ្មងបានហើយ នោះលោកពោលថា "ចំណោរទៅលង់ ខ្លួនបានជាធំ" ជាអំណើះតទៅ អ្នកនឹងបានជាធំ មិនខានឡើយ ។

ត្រង់ណេះបើនឹងពោលយកតាមលំអានបុរាណ នៅកម្ពុជរដ្ឋនេះ បណ្ដាលោកសង្ឃដែលចេះដឹងជ្រៅជ្រះច្បាស់នូវច្បាប់ទម្លាប់ទំនៀមស្រុកព្រមទាំងធម៌វិន័យ ក៏ស្អាតស្អាញគ្មានទើសទាល់ គ្មានធ្វើឲ្យខុសអំពីពុទ្ធោវាទ លោកអង្គនេះទើបបានធ្វើជាសមណសក្តិ កាន់គណសង្ឃ ជារាជាគណៈ ឋានានុក្រម មានគ្រូសូត្រជាដើម, បើលោកអង្គនោះនឹងទ្រាំទ្រសិក្ខាវិន័យពុំបាន លាចាកសិក្ខាបទមកជាគ្រហស្ថវិញ អ្នកនោះគេហៅថា "បណ្ឌិត" គឺជាអ្នកប្រាជ្ញ, បើចូលធ្វើជាខ្ញុំរាជការអម្ចាស់ផែនដី ក៏ច្រើនសព្វព្រះរាជហឫទ័យ ទ្រង់ព្រះមេត្តាឲ្យមាន យសស័ក្តិទីងប្រាក់ខែ ។

សព្វថ្ងៃសោតណា ទូន្មានអាត្មា ដោយនូវក្រឹត្យ
ក្រម បម្រើចាំឆ្ងាយ ឲ្យមានចារិត្ត ទើបខ្លួនជាធំ នៅ
ដល់មហាក្សត្រិយ៍ ។

ន័យខាងលើនេះ មានសេចក្តីថា ឲ្យសិស្សានុសិស្សទូន្មានអាត្មារៀនខ្លួនឲ្យបានតាមលំអានច្បាប់ក្រមនេះជានិច្ចទៅ គឺឲ្យសង្វាតរៀនសូត្រនឹងលំឱតបំរើគ្រូបាធ្យាយ កុំគប្បីធ្វេសប្រហែសភ្លេចខ្លួន បើអ្នកមានចំណេះប្រើការបានហើយ ព្រមទាំងកិរិយាមារយាទត្រឹមត្រូវល្អតាមដំបូន្មាននេះ នឹងមានកិត្តិសព្ទកេរ្តិ៍ឈ្មោះពីរោះខ្ចរខ្ចាយ ទៅដល់ព្រះរាជាជាម្ចាស់ផែនដីពុំខានឡើយ ។

(ពណ៌នាមកយ៉ាងនេះ ព្រោះពីដើមយើងរៀនវិជ្ជាទាំងឡាយតែអំពីវត្ត ដោយពុំមានសាលាបង្រៀន ដូចជាការគណាព្យាបាលសព្វថ្ងៃនេះទេ) ។

ទី ១០- ច្បាប់នេះសោតណា ទុជ្ជានអាត្មា ថេរនៅពុំចាក់ នោះខ្លួនឥតបុណ្យ បម្រើមហាក្សត្រិយ៍ គោរពប្រតិបត្តិ យសនោះពុំលែង ។ ហេតុចានធីងច្បាប់ ចានដូចបង្គាប់ ចិត្តត្រួយល់ស្តេច នោះនៅបម្រើ ស្តេចជាកក្តែង យសនោះពុំលែង ប្រាកដពណ្ណរាយ ។

ន័យពីគៀលនេះ បានសេចក្តីថា បើសិស្សានុសិស្សណា យកចិត្តប្រតិបត្តិ តាមដំបូន្មានលោកជាគ្រូ ដែលបង្ហាត់បង្ហាញមក, នោះខ្លួនឥតយសស័ក្តិអ្វី ហើយចូលទៅនៅគាល់បំរើ "ស្តេចជាតក្តែង" គឺព្រះកជា ជាម្ចាស់ផែនដីដ៏ជាធំ ហើយខ្លួនមានឧស្សាហ៍ គោរពប្រតិបត្តិ ដោយសុចរិតស្មោះត្រង់នោះ សេចក្តីគាប់ប្រសើររុងរឿងពណ្ណរាយ គឺយសស័ក្តិទីងកើតឡើងដល់ខ្លួនពុំលែងឡើយ, ព្រោះដោយអំណាចសេចក្តីប្រតិបត្តិត្រឹមត្រូវតាមច្បាប់គ្រូប្រៀនប្រដៅមកនោះឯង ។

(មានត)

# អំពីតាំងចៅអធិការនិងមន្ត្រីសង្ឃ

ទើបតាំងថ្មីក្នុងខែយ៉ូអាំង-ស៊ុយយេ ឆ្នាំ១៩៥៥

(តពីខែមុនទៀត)

១៨- សញ្ញាប័ត្រលេខ ៣៨ ចុះថ្ងៃ ២៩-៦-៥៥ តាំងលោកគ្រូ ប្រាក់-សយ កើតឆ្នាំកុរ អាយុ ៥១ វស្សា ២០ នាមឆាយា ជាតត្ថេរ ជាចៅអធិការ វត្តដំណាក់ត្រយឹង ឃុំសំរោង ស្រុកបន្ទាយមាស ។

១៩- សញ្ញាប័ត្រលេខ ៣៩ ចុះថ្ងៃ ២៩-៦-៥៥ តាំងលោកគ្រូ ម៉ក់-ឌួន កើតឆ្នាំខាល អាយុ ៣១ វស្សា ៨ នាមឆាយា សុវណ្ណបញ្ញាត្ថេរ ជាចៅអធិការ វត្តកើរកើកដាយ ឃុំវត្តអង្គ ស្រុកបន្ទាយមាស ។

២០- សញ្ញាប័ត្រលេខ ៤០ ចុះថ្ងៃ ២៩-៦-៥៥ តាំងលោកគ្រូ អ៊ឹម-សន កើតឆ្នាំមមី អាយុ ២៥ វស្សា ៥ នាមឆាយា សុវណ្ណជោត ជាចៅអធិការ វត្តសំរោង ឃុំសំរោង ស្រុកបន្ទាយមាស ។

២១- សញ្ញាប័ត្រលេខ ៤១ ចុះថ្ងៃ ២៩-៦-៥៥ តាំងលោកគ្រូ ប៉ោ-ឌី កើតឆ្នាំថោះ អាយុ ៣០ វស្សា ៨ នាមឆាយា សំវរោ ជាចៅអធិការវត្តអម្ពព្រែកក្រាំងជួន ឃុំសំរោង ស្រុកបន្ទាយមាស ។

២២- សញ្ញាប័ត្រលេខ ៤២ ចុះថ្ងៃ ៣០-៦-៤៤ តាំងលោកគ្រូ ព្រះសាក្យវង្ស ហ៊ួត-តាត កើតឆ្នាំកេង អាយុ ៥៣ វស្សា ៣២ ជាគ្រូសូត្រស្តាំ នៅវត្តឧណ្ណាលោម ឃុំលេខ ៣ ក្រុងភ្នំពេញ ។

២៣- សញ្ញាប័ត្រលេខ ៤៣ ចុះថ្ងៃ ៣០-៦-៤៤ តាំងលោកគ្រូ ព្រះគ្រូឧត្តមមុនី ម៉ុង-សែស កើតឆ្នាំថោះ អាយុ ៥៤ វស្សា ៣៣ ជាគ្រូសូត្រឆ្វេង នៅវត្តឧណ្ណាលោម ឃុំលេខ ៣ ក្រុងភ្នំពេញ ។

២៤- សញ្ញាប័ត្រលេខ ៤៤ ចុះថ្ងៃ ២៩-៦-៤៤ តាំងលោកគ្រូ គុំ-ខាត់ កើតឆ្នាំខាល អាយុ ៣១ វស្សា ១០ នាមឆាយា ពុទ្ធរក្ខិត ជាចៅអធិការ វត្តអង្គសួរគ៍ ឃុំកន្ទោរ ស្រុកកំពង់ត្រាច (កំពត) ។

២៥- សញ្ញាប័ត្រលេខ ៥៥ ចុះថ្ងៃ ២៩-៦-៤៤ តាំងលោកគ្រូ ទៅ-កន កើតឆ្នាំម្សាញ់ អាយុ ២៨ វស្សា ៨ នាមឆាយា មុនីសត្ថា ជាចៅអធិការ វត្តអង្គអណ្តែត ឃុំត្រពាំងកំង ស្រុកឈ្ហូក (កំពត) ។

២៦- សញ្ញាប័ត្រលេខ ៤៦ ចុះថ្ងៃ ២៩-៦-៤៤ តាំងលោកគ្រូ ប្រាក់-ម៉ម កើតឆ្នាំជូត អាយុ ៤៤ វស្សា ២៣ នាមឆាយា គន្ធត្ថេរ ជាចៅអធិការ វត្តទទឹងតីរគនាកម ឃុំបឹងស្រង៉ែ ស្រុកឈ្ហូក (កំពត) ។

២៧- សញ្ញាប័ត្រលេខ ៤៧ ចុះថ្ងៃ ២៩-៦-៤៤ តាំងលោកគ្រូ ប៊ី-កួង កើតឆ្នាំខាល អាយុ ៣១ វស្សា ៩ នាមឆាយា ឥន្ទប៉ញ្ញា ជាចៅអធិការ វត្តអង្គចុករង្ស៍ ឃុំបឹងស្រង៉ែ ស្រុកឈ្ហូក (កំពត) ។

២៨- សញ្ញាប័ត្រលេខ ៤៨ ចុះថ្ងៃ ២៩ - ៦ - ៤៤ តាំងលោកគ្រូ គឹម-កែម កើតឆ្នាំម្សាញ់ អាយុ ២៨ វស្សា ៨ នាមឆាយា ធម្មសុវណ្ណ ជាចៅអធិការ វត្តអង្គទៀលពិសី ឃុំបាទៀ ស្រុកឈូក (កំពត) ។

២៩- សញ្ញាប័ត្រលេខ ៤៩ ចុះថ្ងៃ ២៩ - ៦ - ៤៤ តាំងលោកគ្រូ អ៊ុំ - ចោម កើតឆ្នាំរកា អាយុ ៣៦ វស្សា ១៤ នាមឆាយា វិរិយតេជោ ជាចៅអធិការ វត្តម្រះព្រៅ ឃុំឈូក ស្រុកឈូក (កំពត) ។

៣០- សញ្ញាប័ត្រលេខ ៥០ ចុះថ្ងៃ ២៩ - ៦ - ៤៤ តាំងលោកគ្រូ គីម - មឹម កើតឆ្នាំរកា អាយុ ៤៧ វស្សា ២៦ នាមឆាយា បញ្ញាគីរី ជាចៅអធិការ វត្តអង្គគយ ឃុំល្បើក ស្រុកឈូក (កំពត) ។

## រាយនាមមន្ត្រីសង្ឃ

### ដែលបានឡើងសមណសក្តិថ្មី

កាលពីថ្ងៃ ១៧ ខែស៊ូយេ ឆ្នាំ ១៩៤៤ មានព្រះរាជក្រឹត្យតាំងមន្ត្រីសង្ឃទៅជាគណៈជាន់ឯក- ទោ- ត្រី- បក្ខ- នៅវត្តនានាក្នុងក្រុងភ្នំពេញ ដូចមានរាយនាមតទៅនេះ :

## ក - ទីរាជាគណៈជាន់ឯក :

ព្រះពុទ្ធឃោសាចារ្យ ជួន-ណាត ជន្មាយុ ៦០ ឆ្នាំ វស្សា ៤០ រាជាគណៈជាន់ទោ វត្តឧណ្ណាលោម (គណៈមហានិកាយ) ជាទី ព្រះពោធិវង្ស (រាជាគណៈជាន់ឯក) ។

## ១ - រាជាគណៈជាន់ទោ :

ព្រះសាក្យវង្ស ហួត-តាត ជន្មាយុ ៥២ ឆ្នាំ វស្សា ៣២ រាជាគណៈជាន់ត្រី វត្តឧណ្ណាលោម (គណៈមហានិកាយ) ជាទីព្រះមហាវិមលធម្ម (រាជាគណៈជាន់ទោ) ។

## គ - ទីរាជាគណៈជាន់ត្រី :

ព្រះអរិយធម្មមុនី ទែន-ប៊ុល ជន្មាយុ ៥៧ ឆ្នាំ វស្សា ៣៦ រាជាគណៈជាន់ចត្វា វត្តឧណ្ណាលោម (គណៈមហានិកាយ) ជាទីព្រះសាក្យវង្ស (រាជាគណៈជាន់ត្រី) ។

ព្រះញាណវីរិយៈ ទេត-លឿន ជន្មាយុ ៦១ ឆ្នាំ វស្សា ៤០ រាជាគណៈជាន់ចត្វា វត្តខួនមណីកម (គណៈធម្មយុត្ត) ជាទីព្រះធម្មកវីវង្ស (រាជាគណៈជាន់ត្រី) ។

ព្រះវជីរមេធា កែវ-អ៊ួច ជន្មាយុ ៥៥ ឆ្នាំ វស្សា ៣៥ រាជាគណៈជាន់ចត្វា វត្តបទុមវតី (គណៈធម្មយុត្ត) ជាទីព្រះអរិយគស្សប (រាជាគណៈជាន់ត្រី) ។

ព្រះអមរាភិរក្ខិត គង់-ជុំ ជន្មាយុ ៦២ ឆ្នាំ វស្សា ៤១ រាជាគណៈជាន់ចត្វា វត្តបទុមវតី (គណៈធម្មយុត្តិ) ជាទីព្រះឧបាលីវង្ស (រាជាគណៈជាន់ត្រី) ។

## ឃ - ទីភាគគណៈជាន់បត្ថា

ព្រះបាឡាត់អរិយវិមល ពៅ-នេត ជន្មាយុ ៦២ ឆ្នាំ វស្សា ៤០ ឋានា នៅវត្តឧណ្ណាលោម (គណៈមហានិកាយ) ជាទីព្រះអនុមុនី (កជាគណៈជាន់បត្ថា) ។

ព្រះគ្រូ ឧត្តមមុនី ម៉ុង-សេស ជន្មាយុ ៥៤ ឆ្នាំ វស្សា ៣៣ ឋានា វត្តឧណ្ណាលោម (គណៈមហានិកាយ) ជាទីព្រះទេពមុនី (កជា-គណៈជាន់បត្ថា) ។

ព្រះគ្រូ វិមលបញ្ញា យយ-ហ៊ួ ជន្មាយុ ៥៦ ឆ្នាំ វស្សា ៣៤ ឋានា វត្តឧណ្ណាលោម (គណៈមហានិកាយ) ជាទីព្រះធម្មវិបស្សនា (កជាគណៈជាន់បត្ថា) ។

ព្រះបាឡាត់ពោធិកម នួន-គី ជន្មាយុ ៤៧ ឆ្នាំ វស្សា ២៦ ឋានា វត្តឧណ្ណាលោម (គណៈមហានិកាយ) ជាទីព្រះស៊ីរីសុទ្ធ (កជា-គណៈជាន់បត្ថា) ។

ព្រះបញ្ញាចរិយប័ដក ពៅ-ញាណ ជន្មាយុ ៥៤ ឆ្នាំ វស្សា ៣៣ ឋានា វត្តសារាវ័ន (គណៈមហានិកាយ) ជាទីព្រះធម្មវិសុទ្ធវង្ស (កជា-គណៈជាន់បត្ថា) ។

ព្រះគ្រូ វិចិត្តសត្ថា ប៉ាង-គយ ជន្មាយុ ៥៥ ឆ្នាំ វស្សា ៣០ ឋានា វត្តសារាវ័ន (គណៈមហានិកាយ) ជាទីព្រះញាណសំវរ (កជា-គណៈជាន់បត្ថា) ។

# បរិយាយសិប្បកថា

## ព្រះគ្រូសុវិជ្ជាញាណ សួរ-ហាយ ក្រុមជំនុំព្រះត្រៃបិដក

នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

( តមកពីឯចប់ )

សេចក្តីថា "ឲ្យតែឈ្មោះថាសិល្បៈ មើលទៅហាក់ដូចជាផ្តេសផ្តាសទេ តែទៅជាបានការសម្រេចប្រយោជន៍យ៉ាងសន្ធឹក សូមព្រះអង្គពិចារណាមើលចុះ បុរសខ្វិនបានស្រុកសួយ ៤ ទិសក៏ព្រោះតែសិល្បៈផ្ចាត់អាចម៍ពពែ (នោះឯង)" ។

សិល្បៈទាំងអស់ដូចបានពោលមកនេះ ចាត់ជាមង្គលមួយជាហេតុនាំមកនូវសេចក្តីសុខ - ចំរើនរុងរឿងចំពោះស្រុកទេសត្រកូលរបស់ខ្លួនគង់លោកនេះជាប្រាកដ ។ បុរសស្ត្រីអ្នកមានគំនិតថ្លៃថ្នូរយល់ត្រូវ មានព្យាយាមខ្ជាប់ខ្ជួន ស្គាល់ប្រយោជន៍ដ៏ធំទូលាយបានសិក្សាចំពោះសិល្បៈណាមួយឲ្យចេះដឹងស្ទាត់ រមែងបានទទួលផលប្រយោជន៍គឺលាភយស សរសើរ សុខគង់បច្ចុប្បន្នទាន់ភ្នែកដោយជាក់ស្តែង ដូចយ៉ាងលោក-អ្នកទាំងឡាយ ដែលបានឋានន្តរសក្តិយសជាមន្ត្រីធំតូច គង់តំណែងណា ៗ ក៏ដោយ ក៏សុទ្ធតែបានមកដោយសារសិល្បៈទាំងអស់, ខុសគ្នាតែត្រង់ការចេះដឹង គឺអ្នកខ្លះចេះដឹងច្រើន ខ្លះចេះដឹងតិច, អ្នកខ្លះចេះសិល្បៈនេះ, អ្នកខ្លះចេះសិល្បៈនោះប៉ុណ្ណោះ, ពិតណាស់បុគ្គលអ្នក

កាន់ការក្នុងតំណែងនានាដ៏ជាមន្ត្រីមួយៗ ត្រូវជាអ្នកចេះដឹងយល់ការកក់ ផ្ទៅខុសត្រូវឲ្យវែងឆ្ងាយជាងគេអ្នកតូចៗ ទើបបានសេចក្ដីចំរើនទូទៅដល់ប្រទេសជាតិរបស់ខ្លួន, ទាំងប្រជាជនក៏គោរពកោតខ្លាចលាន់មាត់សរសើរថាជាមន្ត្រីខ្ពង់ខ្ពស់ចេះដឹងយល់ប្រយោជន៍ល្អមែន, មិនមែនជាអ្នកល្ងង់ខ្លៅយល់ឃ្លាតអំពីសេចក្ដីចំរើននោះទេ ។

ក្នុងសម័យពុទ្ធកាល, អ្នកស្រុកមជ្ឈិមប្រទេស នោះក្សត្រិយ៍ក្ដី ព្រាហ្មណ៍ក្ដី សេដ្ឋីក្ដី មន្ត្រីក្ដី រាស្ត្រអ្នកមានទ្រព្យក្ដី ច្រើនតែបញ្ជូនកូនចៅឲ្យទៅរៀនសិល្បៈឯនគរតក្កសិលា ព្រោះនគរនោះមានសាលាវិសាបាមោក្ខធំៗ ជាច្រើនសម្បូណ៌ដោយអ្នកប្រាជ្ញចេះដឹងវិជ្ជាគ្រប់យ៉ាង ។ កូនក្សត្រិយ៍, ព្រាហ្មណ៍, សេដ្ឋី, មន្ត្រីនិងកូនរាស្ត្រ ដែលបានទៅរៀនចេះដឹងសម្រេចវិជ្ជាណាមួយហើយ លុះត្រឡប់មកស្រុកវិញទើបបានទទួលឋានន្តរស័ក្តិធំៗ ជាមន្ត្រីកាន់ការផែនដី, ខ្លះបានជាស្ដេច, ខ្លះបានជាសេនាបតី, ខ្លះបានជាមហាមាត្យរាជបណ្ឌិត ។ មន្ត្រីទាំងនោះក្នុងគម្ពីរបាលីច្រើនតែឃើញថា "ឧគ្គហិតសិប្បា" ប្រែថា "អ្នកមានសិល្បៈរៀនស្រេចហើយ" ដូច្នេះ ។ អ្នកដែលបានចុះស្នាមក្នុងផ្លូវសិក្សាសិល្បវិជ្ជា ចេះស្ទាត់ប្រាកដណាស់ ទើបគួរនឹងឲ្យឋានន្តរជាមន្ត្រីធំៗបាន, ព្រោះថា មន្ត្រីទាំងនោះជាអ្នកកាន់បន្ទុកផែនដី បើកកាត់តម្រង់ទៅរកសេចក្ដីចំរើន ។

គម្ពីរធម្មបទ ត្រង់រឿងវិឌូឌភៈ មានរឿងថា "ព្រះរាជកុមារ ៣ អង្គ គឺមួយអង្គព្រះនាមបសេនទិ ជាបុត្ររបស់ស្តេចមហាកោសលក្រុងសាវត្ថី, មួយអង្គព្រះនាមមហាលិ ជាបុត្ររបស់ស្តេចលិច្ឆវីក្រុងវេសាលី, មួយអង្គទៀតព្រះនាមពន្ធុល ជាបុត្ររបស់ស្តេចមល្លៈក្រុងកុសិនារា" ។

ព្រះរាជកុមារទាំង ៣ អង្គនេះបានទៅរៀនសិល្បៈក្នុងសាលាទិសាបាមោក្ខក្រុងតក្កសិលា បានជួបគ្នាសាកសួរគ្រកូលនាមគ្នាទៅវិញទៅមក ស្គាល់គ្នាជាកំលោះហើយក៏រាប់អានស្រឡាញ់ធ្វើជាមិត្តមេត្រីនឹងគ្នា លុះនៅរៀនសូត្រក្នុងទីនោះបានចេះដឹងសិល្បវិទ្យាចប់ស្រេចហើយ ក៏នាំគ្នាលាគ្រូអាចារ្យត្រឡប់មកនគររបស់ខ្លួនវិញ, បណ្តារាជកុមារទាំងនោះ ដែលត្រឡប់មកដល់នគររៀងៗខ្លួនហើយ, បសេនទិកុមារ ក៏បានសំដែងប្ញទ្ធិសិល្បៈថ្វាយសម្តេចព្រះវរបិតា ល្បងមើល ព្រះវរបិតាទ្រង់ពេញព្រះរាជហឬទ័យក្នុងសិល្បវិទ្យារបស់រាជកុមារ ដោយទ្រង់យល់ច្បាស់ថា "បុត្ររបស់អញនេះចេះដឹងប្រសើរមែន គំលើកកាជកុមារអភិសេកឲ្យសោយរាជ្យ" ។ មហាលិកុមារក៏សំដែងសិល្បៈចំពោះពួកក្សត្រិយ៍លិច្ឆវីដោយសេចក្តីប្រឹងប្រែងខ្លាំងពេកក៏បែកភ្នែកទាំងពីរ ។ មហាលិកុមារទោះបែកព្រះនេត្រនោះហើយក៏គង់ក្សត្រិយ៍លិច្ឆវីលើកឲ្យធ្វើជាអាចារ្យបង្រៀនពួកលិច្ឆវីកុមារគេទៅ ។ ចំណែកខាងពន្ធុលកុមារ, ដែលពួកមល្លក្សត្រិយ៍យកឫស្សី ៦០ ដើមហើយយកដែកបុករវ៉ូសលក្នុង

ដើមឫស្សីទាំង៦០ដើម មិនឲ្យពន្ធុលកុមារដឹងថា ឫស្សីមានស្នូលដែក ហើយក៏ចាប់ផ្ដើមលោតឡើងកំពស់ ៨១ ហត្ថ រួចកាប់ផ្ដាច់ឫស្សី ៦០ ដើមនោះឲ្យដាច់ព្រមគ្នាតែចំឡែកត្រង់ដែលឮសំឡេងស្នូលដែកក្រិះៗ ដឹងថាឫស្សីទាំងនោះមានស្នូលដែក ក៏ទឹកភ្នែកតូចចិត្តយំហើយត្រៃរិះជាវែពោលពោលថា "ពួកញាតិទាំងនេះគ្មានអ្នកណាស្រឡាញ់អញប្រាប់ហេតុនេះដល់អញផងសោះ បើដាអញដឹងថាមានដាក់ស្នូលដែកទឹងកាប់ឲ្យដាច់កុំឲ្យឮសូរឲ្យសោះ" លំដាប់នោះ ពន្ធុលកុមារពោលចំពោះព្រះវរមាតាបិតាថា "ខ្ញុំនឹងសំឡាប់ពួកមល្លក្សត្រិយ៍ទាំងអស់នេះហើយទើងសោយរាជ្យ", តែព្រះវរមាតាបិតាឃាត់ខាំងពេកក៏អាក់ខានទៅ ។ ពន្ធុលកុមារគិតឃើញថាអញនឹងទៅរកសំឡាញ់ឯក្រុងសាវត្ថី រួចក៏លាព្រះវរមាតាបិតាទៅរកបសេនទិកុមារជាសំឡាញ់ក្រុងសាវត្ថី លុះទៅដល់ហើយព្រះបាទបសេនទិ ក៏ទទួលត្រេកអរសោទរយ៉ាងមហិមាដោយគិតថា "សំឡាញ់របស់អញជាអ្នកប្រាជ្ញ ឥឡូវនេះមកដល់ហើយ" ។ ព្រះបាទបសេនទិក៏តាំងពន្ធុលកុមារ ក្នុងតំណែងជាសេនាបតីតទៅ ។

រឿងរាជកុមារទាំង ៣ អង្គដែលបាននាំមកដោយសង្ខេបប៉ុណ្ណោះដើម្បីឲ្យឃើញថាមនុស្សសម័យនោះ ស្រឡាញ់ពេញចិត្តនឹងអ្នកប្រាជ្ញដែលចេះសិល្បវិទ្យា ជ្រើសរើសលើកដំកើងឲ្យធ្វើជាមន្ត្រីក្នុងតំណែងណាមួយដោយស្មោះស្ម័គ្រ, មន្ត្រីនោះគេហៅថា "មន្ត្រីសមសក្តិ" ព្រោះ

ប្រកបដោយលក្ខណៈនៃការចេះដឹង ធ្វើការប្រកបដោយព្រហ្មវិហារធម៌ ឲ្យចំរើនប្រយោជន៍ទូទៅដល់ប្រជារាស្ត្រទាំងអស់ ។

ព្រះសម្មាសម្ពុទ្ធរបស់យើងទាំងឡាយ កាលព្រះអង្គនៅជាព្រះពោធិសត្វមិនទាន់បានត្រាស់នៅឡើយ ព្រះអង្គមានព្រះនាមខ្ទរខ្ទាយល្បីល្បាញថា ជាអ្នកចេះដឹងពូកែក្នុងសិល្បវិទ្យាគ្រប់យ៉ាងស្ទើរតែគ្រប់ជាតិដែលព្រះអង្គកើត ដូចមាននិទានមកក្នុងគម្ពីរបាលី-អដ្ឋកថា ឬជាតកជាច្រើនរឿងណាស់ ។

សិល្បៈទាំងឡាយដែលកើតមានឡើងដោយអំណាចបុព្វបុរសអ្នកឈ្លាសវៃចេះរៀនសូត្រនាំៗមកនោះមានច្រើនយ៉ាង គឺសិល្បៈខ្លះជាចំណែកជាន់ខ្ពស់, សិល្បៈខ្លះជាចំណែកជាន់ទាបសម្រាប់រាស្ត្រប្រជាទូទៅ; សិល្បៈដែលពោលមកខាងលើមកនោះមិនបានអស់សព្វគ្រប់ទេ ដូចយ៉ាងសិល្បថ្មីៗដែលកើតមានឡើងតាមជំនាន់កាលសម័យក៏នៅមានច្រើនបែបទៀតណាស់ ។ បុគ្គលជាគ្រហស្ថគួរពិនិត្យជ្រើសរើសមើលសិល្បៈណាដែលត្រូវរៀនទៅហើយនាំឲ្យកើតប្រយោជន៍, ត្រូវសិក្សាចំពោះសិល្បៈនោះចុះ ។ ដូចយ៉ាងការរកទទួលបានខាងរបរស្រែ, ចំការ, លក់ដូរ របស់គ្រហស្ថដែលថ្នាក់ស្ទាត់ប៉ិនប្រសប់ក្នុងការនោះៗ ក៏ហៅថា សិល្បៈដែរ ។ ការងារខាងស្រែចំការ ហៅថាកសិកម្មសិប្បៈ គឺសិល្បៈក្នុងការភ្ជួររាស់ សាបព្រោះ-ដកស្ទូង, ការងារខាងជួញប្រែលក់

ដូរហៅថា វណិជ្ជសិប្ប: ។ សិល្ប:ទាំងអស់មិនចំពោះសិល្ប:ណាឡើយ សុទ្ធតែនាំឲ្យបានទ្រព្យសម្បត្តិ តែបើមនុស្សខ្ជិលច្រអូស មិនមានព្យាយាមខ្ជាប់ខ្ជួន មិនមានឧបាយប្រាជ្ញាអមជាមួយផងទេ ក៏បានប្រយោជន៍តិច, លុះតែមានព្យាយាមមានឧបាយយល់ត្រូវល្អ ទើបបានផលប្រយោជន៍ច្រើន ៗ អ្នកដែលគ្មានដីស្រែ, ចំការ ច្រើនតែបេះស្ទាត់ខាងវណិជ្ជសិល្ប:គឺរបរខាងការលក់ដូរ, សិល្ប:នេះគេរាប់ថាជាធំបំផុត ឆាប់បានទ្រព្យសម្បត្តិឡើងទៅជាអ្នកមានទ្រព្យទៅជាសេដ្ឋី ជាងសិល្ប:ឯទៀត ៗ ។

គន្លងឬផ្លូវនៃវណិជ្ជសិល្ប:នេះជាផ្លូវធំវែងឆ្ងាយ មិនចាប់ចំលងផ្លូវដូចកសិកម្មសិល្ប:ទេ, ព្រោះការលក់ដូរនេះ មិនមានកំណត់ផ្លូវ មិនមានកំណត់ទីកន្លែងមួយ ៗ នោះឡើយ ។

ផ្លូវរបស់វណិជ្ជសិប្ប:ការជួញប្រែនេះមាន ៤ យ៉ាង:

១- ឃរវណិជ្ជា ការលក់ដូរទំនិញផ្សេងៗ ដែលទុកដាក់នៅក្នុងផ្ទះក្នុងផ្សារ,

២- ចារាវណិជ្ជា ការលក់ដូរទំនិញផ្សេងៗ ដែលនៅក្នុងនាវ តំទូក ឬកប៉ាល់,

៣- សកដវណិជ្ជា ការលក់ដូរទំនិញផ្សេងៗ នៅក្នុងរទេះ ឬដឹកនាំដោយរទេះទៅលក់ដូរ,

៤- ជនឆ្លៀវឆ្លាត ការលើកវត្ថុទំនិញផ្សេងៗ ក្នុងវេមែក ឬ សម្ភាយដែលទៅដោយកំឡាំងស្ទួន ៗ

ពួកជនអ្នកប្រាថ្នាទ្រព្យសម្បត្តិឲ្យធាប់ចំរើន ដើម្បីឲ្យបានចួបប្រទះនឹងភោគសុខ ឬហៅថាលាភសុខ ក្នុងលោកនេះ ត្រូវប្រើកំឡាំងព្យាយាមនឹងការត្រិះរិះក្នុងសិល្បៈណាមួយឲ្យរៀយ ៗ ។ គុណជាតិដែលមនុស្សបុថុជ្ជនតែងប្រាថ្នានោះមាន ៤ យ៉ាងគឺ លាភោ បានទ្រព្យវត្ថុណាមួយជាទីពេញចិត្ត ១, យសោ រុងរឿងដោយបរិវារ ១, បសំសា អ្នកផងសរសើរ ១, សុខំ សប្បាយកាយ-ចិត្ត ១ ។ គុណ[illegible]តទាំង ៤ នេះពាក់ជាឥដ្ឋារម្មណ៍គឺជាទីប្រាថ្នាជាទីត្រេកអរ របស់បុថុជ្ជនទាំងអស់ ៗ បុគ្គលអ្នកប្រាថ្នាចំពោះឥដ្ឋារម្មណ៍នេះ; បើគ្រាន់តែប្រាថ្នាបង់[illegible]ន តែបើខ្ជះខ្ជាយៈ សេចក្តីព្យាយាមមាំមួនជាកំឡាំងជួយផង ក៏មិនដែលបានសម្រេចដូចប្រាថ្នាឡើយ, ដូចអ្នកបង់បានប្រេងដូង ឬអ្នកបង់[illegible]ទនេទៅត្រើយម្ខាង, បើមិនមានព្យាយាមពុះបំបែកដូងទុំឆ្កៀលយក[illegible]ចហើយបំពាក់ទេ តើដូងទុំនឹងចេញប្រេងមកឲ្យដែរឬ? បើមិនមានព្យាយាមណានាំដើរចុះទៅពីមាត់ត្រាំងទៅរកទូកឬកញ្ចាល់ទេ [illegible] ទូកកញ្ចាល់មកពួកនេកមនុស្សនៅលើមាត់ត្រាំងបានដែរឬ? ដូងទុំក៏មិន[illegible]បចេញប្រេងមកឲ្យបាន, ទូកឬកញ្ចាល់ក៏ចម្លងមនុស្សនៅលើមាត់ត្រាំងមិនកើត;

សេចក្ដីនេះយ៉ាងណាមិញ មនុស្សអ្នកចង់បានឥដ្ឋារម្មណ៍ តែបើខ្វះវីរិយៈ និងបញ្ញាក៏មិនងាយនឹងបានចួបប្រទះយ៉ាងនោះដែរ ។

មនុស្សក្នុងត្រកូលនីមួយៗ ក្នុងផ្ទះមួយៗ ដែលមានបងប្អូនកូនចៅច្រើន តែមានដីស្រែចំការតិច ធ្វើមិនបានផលបរិបូណ៌ មិនគ្រប់គ្រាន់ដល់ការចាយវាយគ្នាច្រើន គួរតែរំលែកបំបែកគ្នាចេញខ្លះ ដើម្បីនឹងបែកមុខគ្នា សិក្សារៀនសូត្រវិជ្ជាសិល្បៈផ្សេងៗ ឬគួរបែកមុខរបររកទទួលទានដោយសេចក្ដីព្យាយាមប្រឹងប្រែងដោយខ្លួនៗ ពីគ្នាគឺអ្នកខ្លះរកទទួលទានរបរនេះ អ្នកខ្លះរកទទួលទានរបរនោះ, អ្នកខ្លះស្វះស្វែងទៅស្រុកឆ្ងាយ, អ្នកខ្លះនៅជិតៗ, អ្នកខ្លះទៅខាងជើងគោក, អ្នកខ្លះទៅខាងជើងទឹក អ្នកខ្លះចេញទៅទិសឯណេះ, អ្នកខ្លះចេញទៅទិសឯណោះ ។

កាលសម័យរបស់ស្រុកទេសនីមួយៗ ក្នុងលោកឥឡូវនេះចង្អៀតមិនមែនធូរទូលាយដូចកាលសម័យពីដើមទេ ដូចជាយើងបានប្រទះមកហើយ, បើកាលសម័យចេះតែវិលអណ្ដែតដើរលឿនចង្អៀតញឹកញាប់យ៉ាងនេះ, យើងជាអ្នកកើតមកផ្ទកកោនក្រោមម្លប់ របស់ការវេហា ប្រភើរ ឈើ អង្គុយ ដេក លើផែនដី; យើងត្រូវតែប្រើកំឡាំងកាយ ចាយកំឡាំងនៃសេចក្ដីព្យាយាម, សេចក្ដីត្រិះរិះគិតគួរឲ្យទ្វេឡើងញឹកញាប់ជឿនលឿនតាមចង្វាក់នៃកាលសម័យរបស់ស្រុកទេស ទើបឈ្មោះថាជាអ្នកស្គាល់សេចក្ដីចំរើនមែន ។ កាលវេលាស្រុកទេសពីដើមហាក់

ដូចជាដើរយឺតៗ រង្វើលៗ ព្រោះមនុស្សតិច, បុព្វបុរសគឺជីដូនជីតាគង់កាលមុនរបស់យើងក៏ប្រកបការងារព្យាយាមយឺតៗ រង្វើលៗ ដូច្នោះដែរ រូបយើងឥឡូវនេះ នឹងខ្ចីយកកាលសម័យជាន់នោះមកប្រើជាគំរូដូច្នោះ ពុំសមតាមកាលវេលាឡើយ, ប្រៀបដូចជាតូរ្យតន្ត្រីដែលពួកអ្នកលេងដេញដំផ្លុំគួត ឲ្យមានបទភ្លេងញឹកញាប់ ចំណែកខាងអ្នកច្រៀងក៏ត្រូវតែច្រៀងលោកសំឡេងបទនោះឲ្យញឹកញាប់ គង់ធូរតាមចង្វាក់ភ្លេងដូច្នោះដែរ ទាំងអ្នករាំអ្នកឡ្យក ក៏ត្រូវតែរាំត្រូវតែឡ្យកឲ្យញាប់តាមភ្លេងនោះទៀតដែរទើបហៅថាអ្នកលេងមានរបៀបបទប្រាកដឈ្មោសរៃគង់តារច្រៀងរាំ, បើច្រៀងរាំ ឬឡ្យកខុសពីចង្វាក់ភ្លេងឈ្មោះថាអ្នកលេងមិនប្រសប់ក្នុងការលេង ។

កាលសម័យស្រុកទេសឥឡូវនេះបង្អៀតញឹកញាប់ យើងក៏ត្រូវប្រកបកិច្ចការឲ្យញឹកញាប់ លឿនរហ័សតាមរយៈចង្វាក់នៃកាលសម័យដូចអធិប្បាយមកនេះឯង ។

ចប់បរិយាយសិប្បកថាតែប៉ុណ្ណេះ ។